# ឯកសារគោលនយោបាយសង្ខេប
# សំរាប់
# សន្និសីទបណ្តាភាគីជាសមាជិកនៃអនុសញ្ញា
# ក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
# លើកទី ២១ នៅទីក្រុងប៉ារីស (CoP21)

## ទស្សនៈរបស់ប្រទេសកម្ពុជាចំពោះអាទិភាព និង កាលៈទេសៈពិសេស
## ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលងាយរងគ្រោះពីអាកាសធាតុ

រៀបរៀងដោយលោក តូម៉ាស ហឺស្ស (**THOMAS HIRSCH**) និងលោក ធីសាន់ក័រ ម៉ែនដាល (**TIRTHANKAR MANDAL**) នៃក្រុមហ៊ុនផ្តល់ប្រឹក្សា ផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (**CLIMATE & DEVELOPMENT ADVICE**)

PARIS2015
UN CLIMATE CHANGE CONFERENCE
COP21·CMP11

**ខែ កក្កដា ឆ្នាំ ២០១៥**

# ឯកសារគោលនយោបាយសង្ខេប

# សំរាប់

# សន្និសីទបណ្តាភាគីជាសមាជិកនៃអនុសញ្ញា

# ក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ

# លើកទី ២១ នៅទីក្រុងប៉ារីស (CoP21)

## ទស្សនៈរបស់ប្រទេសកម្ពុជាចំពោះអាទិភាព និង ភាពៈទេសៈពិសេស

## ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលងាយរងគ្រោះពីអាកាសធាតុ

រៀបរៀងដោយលោក តូម៉ាស ហឺស្ស (Thomas Hirsch) និងលោក ធីសាន់គ័រ ម៉ែនដាល (Tirthankar mandal) នៃក្រុមហ៊ុនផ្តល់ប្រឹក្សា ផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice)

គម្រោង DIPECHO គឺគម្រោងសហការនៃអង្គការ ActionAid, DanChurchAid/ ChristianAid, Oxfam, People and Need និង Save the Children។ ក្រុមអង្គការទាំងនេះ ធ្វើការដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការបន្ទាន់ និង សមត្ថភាពរបស់ភាគីពាក់ព័ន្ធ និងសហគមន៍ពាក់ព័ន្ធនានា ដើម្បីកាត់បន្ថយហានិភ័យបង្កដោយគ្រោះមហន្តរាយ និងអាកាសធាតុរបស់ពួកគេ។

ឯកសារសង្ខេបគោលនយោបាយនេះ ត្រូវបានរៀបចំក្រោមគម្រោង DIPECHO BDRC II ដោយសហការជាមួយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia)

*ឯកសារនេះ គ្របដណ្តប់លើសកម្មភាពជំនួយមនុស្សធម៌ដែលត្រូវបានអនុវត្តដោយមានជំនួយហិរញ្ញវត្ថុនៃសហភាពអឺរ៉ុប។ ទស្សនៈដែលត្រូវបានបង្ហាញក្នុងឯកសារនេះ ទោះជាតាមវិធីណាក៏ដោយ មិនគប្បីត្រូវចាត់ទុកថាឆ្លុះបញ្ចាំងយោបល់ផ្លូវការរបស់សហភាពអឺរ៉ុបទេ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវលើការប្រើប្រាស់ណាដែលឯកសារនេះអាចបង្ហាញឡើយ។*

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូសម្គាសន៍ខាងក្រោម ក្រុមអង្គការគម្រោង DIPECHO និង ដៃគូ ដែលបានរួមចំណែកយ៉ាងច្រើនចំពោះការសិក្សានេះ ដោយចែករំលែកជំនាញ និងផ្តល់យោបល់ក្នុងការសិក្សានេះ ក្នុងនោះរួមមាន ៖ លោក ហារ៉ល ហ្គេគ័រ (Harald Guelker) អ្នកសម្របសម្រួលគម្រោង DIPECHO, លោកស្រី អាលីន មិឡេហ្វ (Aline Milev) អ្នកសម្របសម្រួលកម្មវិធីអង្គការ DCA/CA, លោក ទេព ប៊ុននី ប្រធានក្រុមប្រឹក្សាភិបាលនៃបណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCN), លោក អ៊ុក ណាវ៉ាន់ អគ្គនាយករង នៃក្រសួងបរិស្ថាន, លោកស្រី ហ៊ីង ភាវ៉ានិច អ្នកវិភាគការប្រែប្រួលអាកាសធាតុ នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង លោក ស៊ូ សុជាតិ នាយកប្រតិបត្តិ នៃអង្គការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានកម្ពុជា ។ លោក សី ពៅ អ្នកសម្របសម្រួលគម្រោងតាមដានគោលនយោបាយប្រែប្រួលអាកាសធាតុ និង គណៈកម្មការដឹកនាំសម្ពន្ធ័អង្គការមិនមែនរដ្ឋាភិបាលស្តីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ (NECA) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលបានចូលរួមកែសំរួល និងបកប្រែជាភាសាខ្មែរ។ សូមអរគុណជាពិសេសចំពោះ លោក ណុប ប៉ូលីន ទីប្រឹក្សាផ្នែកប្រែប្រួលអាកាសធាតុនៃអង្គការ DCA/CA ដែលបានផ្តល់ការណែនាំ និងមតិយោបល់។

ទស្សនៈ ទាំងឡាយដែលត្រូវបានសម្តែងក្នុងឯកសារសង្ខេបនេះ គឺមិនមែនជាទស្សនៈរបស់អ្នកនិពន្ធនោះទេ។

# ពាក្យបំព្រួញ និង អក្សរកាត់

| | | |
|---|---|---|
| ACT | Action of Churches Together | សកម្មភាពនៃព្រះវិហាររួមគ្នា |
| ADP | UNFCCC Ad Hoc Working Group of the Durban Platform on Enhanced Action | ក្រុមការងារចំពោះកិច្ច UNFCCC នៃវេទិកាក្រុងឌ័របិនសំរាប់សកម្មភាពកែលម្អ |
| AILAC | Association of Independent Latin American Countries | សមាគមនៃប្រទេសឯករាជ្យនៅអាមេរិកឡាទីន |
| AOSIS | Association of Small Island States | សមាគមនៃរដ្ឋកោះតូចៗ |
| BASIC | Brazil, China, India & South Africa | ប្រទេសប្រេស៊ីល ចិន ឥណ្ឌា និង អាហ្វ្រិកខាងត្បូង |
| COP | Conference of Parties | សន្និសីទបណ្តាភាគីជាសមាជិកនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| G7 | Group of the 7 most relevant industrialized countries | ក្រុមប្រទេសឧស្សាហូបនីយកម្មខ្ពស់បំផុតទាំង ៧ |
| G20 | Group of the 20 most relevant industrialized countries and emerging economies | ក្រុមប្រទេសឧស្សាហូបនីយកម្មខ្ពស់បំផុត និងប្រទេសមានសេដ្ឋកិច្ចលូតលាស់ថ្មីទាំង ២០ |
| GHG | Greenhouse gases | ឧស្ម័នផ្ទះកញ្ចក់ |
| INDC | Intended Nationally Determined Contribution | ការចូលរួមថ្នាក់ជាតិតាមការគ្រោងទុក ក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDCs) |
| IPCC | International Panel on Climate Change | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| LCD | Least Developed Countries | ប្រទេសអភិវឌ្ឍតិចតួច |
| LMDC | Like Minded Developing Countries | ប្រទេសកំពុងអភិវឌ្ឍដែលមានគំនិតដូចគ្នា |

| | | |
|---|---|---|
| MRV | Measurement, Reporting & Verification | ការវាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ |
| NAP | National Adaptation Plans | ផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NAPA | National Adaptation Program of Action | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| ODA | Official Development Assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| OECD | Organization for Economic Cooperation and Development | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| SIDS | Small Island Developing States | រដ្ឋកោះតូចៗកំពុងអភិវឌ្ឍ |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| WIM | Warsaw International Mechanism | យន្តការអន្តរជាតិក្រុងវ៉ាស្សូវី |
| WS 1 & 2 | ADP Workstream 1 & 2 | លំហូរការងារទី ១ និង ២ នៃ ADP |

# មាតិកា

ពាក្យបំព្រួញ និង អក្សរកាត់ ........ ៤
មាតិកា ........ ៦
សេចក្តីសង្ខេបរួម ........ ៧
ជម្រើសគោលនយោបាយសំខាន់ៗ ........ ៨
សេចក្តីផ្តើម ........ ៩
វិធីសាស្រ្ត ........ ១៣
របកគំហើញ និង សេចក្តីសន្និដ្ឋានស្តីពីស្ថានភាពនៃកិច្ចការនៅក្នុងការជជែកអំពីអាកាសធាតុ... ១៥
កិច្ចដំណើរការអន្តរជាតិដែលនាំទៅដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ........ ១៥
ឯកសារចរចារបច្ចុប្បន្ន និង សមាសភាគគន្លឹះទាំងឡាយរបស់វា ........ ១៨
លទ្ធភាពស្តាបត្យកម្មនិងទម្រង់ច្បាប់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ........ ១៩
អាទិភាពគោលនយោបាយប្រែប្រួលអាកាសធាតុកម្ពុជា ........ ២០
ជំហរគន្លឹះនៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ........ ២២
ជម្រើលគោលនយោបាយដើម្បីសម្រេចបានលទ្ធផលប្រសើរបំផុតដែលអាចមាន ........ ២៤
- គោលដៅរយៈពេលវែង ........ ២៤
- ការពិនិត្យវាយតម្លៃទៀងទាត់ដើម្បីបង្កើនការសន្យានិងសកម្មភាពជាបណ្តើរៗ ........ ២៥
- តម្លាភាព និង គណនេយ្យភាពនៃសកម្មភាពនិងការគាំទ្រ ........ ២៦
- ការបន្សាំ និង ការបាត់បង់ និង ការខូចខាត - ពង្រឹងភាពធន់នឹងអាកាសធាតុ ........ ២៨
- ការកៀងគរហិរញ្ញប្បទានអាកាសធាតុ ការផ្ទេរបច្ចេកវិទ្យា និង ការកសាងសមត្ថភាព ........ ៣០
- ការភ្ជិតគម្លាតមហិច្ឆតាមុនឆ្នាំ ២០២០ ........ ៣២
ឧបសម្ព័ន្ធ ........ ៣៣
អំពីអ្នកនិពន្ធ ........ ៣៣
ដៃគូសម្ភាសន៍ ........ ៣៣
ឯកសារសិក្សា ........ ៣៣
ផែនទីបង្ហាញផ្លូវនៃក្រុមប្រទេសសំខាន់ៗនៅក្នុងកិច្ចដំណើរការអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ........ ៣៥

# សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជា បានបង្កើតយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមួយសំដៅពង្រឹងភាពធន់នឹងអាកាសធាតុ និងកែលម្អការប្រើថាមពលកកើតឡើងវិញ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ខ្លួន ។ ជាក្រុមប្រទេស LDC កម្ពុជាកំពុងរំពឹងទុកនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីសប្រកបដោយមហិច្ឆតាមួយ ដែលត្រូវអនុវត្តចំពោះគ្រប់ប្រទេសជាសមាជិកនៃ UNFCCC និងអ្នកទទួលផល ដើម្បីឆ្លើយតបទៅនឹងភាពងាយរងគ្រោះរបស់ប្រទេស។ ឯកសារសង្ខេបនេះ បានពិភាក្សាស្ថានភាពបច្ចុប្បន្ន (ខែ កក្កដា ឆ្នាំ ២០១៥) នៃការចរចារអាកាសធាតុ ពាក់ព័ន្ធនឹងនីតិវិធី ខ្លឹមសារ និងទម្រង់ច្បាប់។ សេណារីយ៉ូសម្រាប់ជំហានបន្ត នឹងត្រូវបង្ហាញជូននៅក្នុងឯកសារនេះ ហើយជម្រើសគោលនយោបាយជាបន្ត ដែលជាអាទិភាពរបស់ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវបានសិក្សាវាយតម្លៃ។ ជាចុងក្រោយ ឯកសារសង្ខេបនេះនឹងផ្តល់ជូននូវអាទិភាពជាយុទ្ធសាស្ត្រមួយចំនួន ដើម្បីសម្រេចបាននៅទីក្រុងប៉ារីស។

## ជម្រើសគោលនយោបាយសំខាន់ៗ

ដូចបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀតជាច្រើន និងក៏ដូចជាប្រទេសជិតខាង ដូច្នោះដែរ កម្ពុជា គឺជាប្រទេសរងការគម្រាមកំហែងដោយសារការប្រែប្រួលអាកាសធាតុ។ ជាការឆ្លើយតប ប្រទេសកម្ពុជាបានលើកឡើងនូវយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីភ្ជិតគម្លាត កាត់បន្ថយហានិភ័យកែលម្អភាពធន់ និងប្រើសក្តានុពលនៃបច្ចេកវិទ្យាបញ្ចេញកាបូនទាបសម្រាប់ការអភិវឌ្ឍ។ សន្និសីទបណ្តាភាគីអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២១ (COP២១) ផ្តល់ឱកាស ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ និងដៃគូ ដើម្បីផ្សារភ្ជាប់កិច្ចដំណើរការសហការថ្នាក់ជាតិ និងអន្តរជាតិ និង ដើម្បីរួមចំណែកសម្រួលដល់លក្ខខណ្ឌអំណោយផល ក្នុងក្របខណ្ឌការងារអន្តរជាតិ ដែលអាចនាំទៅដល់សកភាជថ្មីមួយនៃក្នុងដំណើរការកិច្ចសហការអន្តរជាតិ។ ប្រទេសកម្ពុជា អាចរួមចំណែកដល់ការចាប់ផ្តើមនៃសកភាជថ្មីនេះ ដោយប្រកាន់យកជំហរមុតមាំ និងប្រកបដោយការតាំងចិត្តនៅក្នុងការជជែកអំពីអាកាសធាតុ។ តាមការសិក្សាវាយតម្លៃនេះ យើងសូមផ្តល់អនុសាសន៍សង្ខេបសំរាប់ពិចារណាលើអាទិភាពជាយុទ្ធសាស្ត្រដូចខាងក្រោម៖

- គោលដៅរយៈពេលវែង៖ ប្រកាន់ជំហរស្របទៅនឹងគោលដៅកម្រិតសីតុណ្ហភាពឲ្យនៅត្រឹម ១,៥/២°C ជាមួយនឹងគោលដៅមិនបញ្ចេញសារធាតុកាបូនដុល។ការអនុវត្តជាបណ្តើរៗ៖ បង្កើតយន្តការ ត្រួតពិនិត្យ និងជំរុញបន្ថែម
- ក្របខណ្ឌតម្លាភាពជាមួយគោលការណ៍ដែលអាចវាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV) សម្រាប់ប្រទេសទាំងអស់ លើកលែងតែប្រទេស LDC និង SIDS
- គោលដៅបន្សុំាំ ដែលទ្រទ្រង់ដោយក្របខណ្ឌស្ថាប័ន និង ការគាំទ្រភាពធន់
- ការទទួលស្គាល់ការបាត់បង់ និងការខូចខាត ព្រមទាំង ការពង្រឹងយន្តការអន្តរជាតិក្រុងវ៉ាសូវី (WIM) ដែលមានចែងក្នុងកិច្ចព្រមព្រៀង
- ការធានាហិរញ្ញវត្ថុអាចព្យាករណ៍បានយ៉ាងហោចណាស់ ១០០ ពាន់លានដុល្លារ ដោយ ផ្តល់លទ្ធភាពអនុគ្រោះដល់ប្រទេស LDC/SIDS
- ជំហានបន្ថែមដើម្បីភ្ជិតគម្លាតមុនឆ្នាំ ២០២០ ដែលត្រូវ វាយតម្លៃប្រចាំឆ្នាំដោយថ្នាក់រដ្ឋមន្ត្រីក្រោមយន្តការ ADP WS២

# សេចក្តីផ្តើម

ឯកសារសង្ខេបគោលនយោបាយនេះ សំដៅគាំទ្រជំហរ និងការចូលរួមដ៏សកម្មរបស់កម្ពុជាក្នុងការជជែកអំពីអាកាសធាតុឆ្នាំ ២០១៥ ដែលនាំទៅដល់ COP២១ នៅក្រុងប៉ារីស។ ឯកសារសង្ខេបនេះត្រូវបានរៀបរាងឡើង ដោយយោងថា ប្រទេសកម្ពុជាជាប្រទេសមួយនៃបណ្តាប្រទេស ងាយរងគ្រោះបំផុតពីអាកាសធាតុក្នុងពិភពលោក[1] ដែលត្រូវប្រកាន់យកជំហរនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) និង ដោយបានកំណត់អាទិភាពជាតិរបស់ខ្លួននៅក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៤-២០២៣ ដែលបានអនុម័តដោយព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៣។ ឯកសារសង្ខេបគោលនយោបាយនេះ ពិព័ណ៌នាអំពីស្ថានភាពបច្ចុប្បន្ននៃការចរចាក្រោមអនុសញ្ញា UNFCCC ដែលត្រូវបានរំពឹងទុកថានឹងនាំទៅដល់ការអនុម័តកិច្ចព្រមព្រៀងអាកាសធាតុក្រោយឆ្នាំ ២០២០ ដែលជាកាតព្វកិច្ចផ្លូវច្បាប់មួយ និងត្រូវអនុវត្តចំពោះបណ្តារដ្ឋភាគីទាំងអស់នៅទីក្រុងប៉ារីសក្នុង COP21 ។ បើប្រៀបធៀបស្ថានភាពបច្ចុប្បន្ន នៃការចរចារជាមួយអាទិភាពរបស់កម្ពុជា និងបើឆ្លុះបញ្ចាំងពីជំហរសំខាន់ៗនៃក្រុមប្រទេស LDC សេណារីយ៉ូ និងជម្រើសគោលនយោបាយផ្សេងៗនឹងត្រូវបង្ហាញនិងពិភាក្សា។ អ្នកនិពន្ធ សន្និដ្ឋាន ដោយភ្ជាប់នឹងអនុសាសន៍កម្រិតគោលនយោបាយ ដែលអាចជួយភាគីពាក់ព័ន្ធកម្ពុជា ជាអាទិ៍ សង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដើម្បីកំណត់គោលជំហររបស់ខ្លួន និងចូលរួមក្នុងដំណើរការចរចាររបស់ UNFCCC តាមវិធីមួយដែលនាំទៅដល់លទ្ធផលប្រសើរបំផុត ប្រកបដោយការគិតគូរអំពីតម្រូវការ និងអាទិភាពរបស់ប្រទេស។

ឆ្នាំ ២០១៥ គឺជាឆ្នាំកំណត់ដើម្បីសម្រេចកិច្ចព្រមព្រៀងអន្តរជាតិមួយស្តីពីអាកាសធាតុ សំដៅបង្កើតលក្ខខណ្ឌក្របខណ្ឌនយោបាយ និងសេដ្ឋកិច្ចអន្តរជាតិ សំដៅរក្សាការឡើងកម្តៅភពផែនដីនៅក្រោមកម្រិតសីតុណ្ហភាព ១,៥/២°C ។ កិច្ចប្រជុំកំពូលសហប្រជាជាតិស្តីពីអាកាសធាតុ ឆ្នាំ ២០១៥ នៅទីក្រុងប៉ារីស រំពឹងថានឹងក្លាយជារបត់មួយនៅក្នុងការតស៊ូប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ហើយអ្វីដែលសំខាន់នោះ គឺការចរចារចាប់តាំងពី COP ទី១៥ នៅក្រុងកូប៉េនហាក (ឆ្នាំ ២០០៩)។

ប៉ុន្តែចំណុចនេះមិនមែនមានន័យថា កិច្ចព្រមព្រៀងនោះ នឹងភ្ជិតគម្លាតអាកាសធាតុបានទេ ។ កិច្ចការនេះ ស្ទើរតែមិនអាចធ្វើបាន ចំពោះមុខការសន្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិដែលបានលើកឡើងដោយរដ្ឋជាសមាជិក នាពេលកន្លងមក ពោលគឺនៅតែស្ថិតនៅឆ្ងាយ

[1] បន្ទាប់ពីប្រទេសហ្វីលីពីន កម្ពុជាជាប់ចំណាត់ថ្នាក់ទីពីរនៅក្នុងសន្ទស្សន៍ហានិភ័យអាកាសធាតុពិភពលោក (Global Climate Risk Index) ឆ្នាំ ២០១៥ បោះពុម្ពផ្សាយដោយ Germanwatch, https://germanwatch.org/de/download/10333.pdf

ពីកម្រិតមហិច្ឆតាដែលចាំបាច់ ដើម្បីរក្សាកម្រិតសីតុណ្ហភាពមិនឲ្យលើសពី ១,៥/២°C។ ប្រសិនបើមិនអាចកំណត់មួយប្រកបដោយមហិច្ឆតាទេនោះ សំណួរសួរថាតើសន្និសីទទីក្រុងប៉ារីស វានឹងមានសារៈសំខាន់ប៉ុណ្ណា? ក្រៅពីការប្តេជ្ញារបស់រដ្ឋជាសមាជិកកាន់តែច្រើនឡើងចំពោះការឯកភាពរួមលើការសន្យាម៉ឺងម៉ាត់រយៈពេលវែងមួយ ទៅតាមមាគ៌ាធន់នឹង អាកាសធាតុដែលបញ្ចេញកាបូនទាប ស្របតាមគោលដៅសីតុណ្ហភាពឲ្យនៅត្រឹម ១,៥/២°C សក្តានុពលនៃកិច្ចព្រមព្រៀងក្រុងប៉ារីស គឺផ្អែកលើលទ្ធភាពបង្កើតយន្តការមួយ ដែលអនុវត្តបានចំពោះគ្រប់រដ្ឋភាគីសមាជិក ដែលជួយសម្រួលឲ្យមានតម្លាភាព គណនេយ្យភាព ការកំណត់ចំណុចកំពូលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មុនពេលកំណត់ និងការបង្កើនជាបណ្តើរៗ នូវវិភាគទានចូលរួមអនុវត្តអនុសញ្ញា នៅថ្នាក់ជាតិ។

ចំពោះទម្រង់ច្បាប់ សន្និសីទទីក្រុងប៉ារីសត្រូវបានរំពឹងថានឹងសម្រេចបានកិច្ចព្រមព្រៀងដែលជាកាតព្វកិច្ចផ្លូវច្បាប់ ដែលត្រូវបំពេញបន្ថែមដោយសេចក្តីសម្រេច COP នានា និងរបៀបវារៈដំណោះស្រាយមួយ។ កញ្ចប់នេះ នឹងផ្តល់ចក្ខុវិស័យគ្មានកាបូនរយៈពេលវែងមួយ ដែលត្រូវបានគាំទ្រដោយយន្តការគណនេយ្យ និងត្រួតពិនិត្យវាយតម្លៃជាលក្ខណៈសកល ក៏ដូចជាគាំទ្រកាត់បន្ថយការបញ្ចេញកាបូនជាជំហានៗ និងកសាងភាពធន់នឹងអាកាសធាតុ។ កិច្ចប្រជុំក្រុងប៉ារីសដែលនឹងក្លាយជាការសម្រុះសម្រួលគ្នា គឺចាំបាច់ត្រូវជំរុញកិច្ចសហការ និងសាមគ្គីភាពរវាងប្រទេសជាតិ។

តើការគិតដូច្នេះ វានឹងអាច កើតឡើងឬទេ? វាគឺជាប្រការគួរឲ្យចាប់អារម្មណ៍ ដែលគេសង្កេតឃើញថា ដំណើរការចរចាររបស់ UNFCCC បានបោះជំហានយឺតច្រើនជាងប្រការដែលលក្ខខណ្ឌក្របខណ្ឌពិភពលោកពិតៗបានផ្លាស់ប្តូរ ចាប់តាំងពីបរាជ័យក្រុងកូប៉េនហាកក្នុងឆ្នាំ ២០០៩។ និន្នាការចំនួនប្រាំពីរ បានផ្តល់នូវមូលហេតុសម្រាប់ក្តីសង្ឃឹមថា សន្និសីទទីក្រុងប៉ារីស នឹងសម្រេចបាន៖

**១.** មូលដ្ឋានវិទ្យាសាស្ត្រដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍វាយតម្លៃលើកទី ៥ នៃក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) មានលក្ខណៈច្បាស់លាស់ ៖ មានការយល់គ្នាទូលំទូលាយមួយថា ថា ការបញ្ចេញឧស្ម័នពិភពលោកត្រូវតែឈានដល់កម្រិតកំពូលមុនឆ្នាំ ២០២០ និងថយចុះយ៉ាងខ្លាំងមកវិញក្រោយពេលកាត់បន្ថយហានិភ័យអាកាសធាតុ។ ការមន្ទិលសង្ស័យលើអាកាសធាតុកំពុងថយចុះ។

**២.** ផលប៉ះពាល់អាកាសធាតុជាអវិជ្ជមាន កំពុងត្រូវបានគេជួបប្រទះជាសកល។ បាតុភូតនៃធាតុអាកាសហួសប្រមាណ ដូចជារលកកម្តៅ គ្រោះទឹកជំនន់ ព្យុះ និងគ្រោះរាំងស្ងួត បាននិងកំពុងកើនឡើង ដែលនាំទៅដល់ការបាត់បង់ផ្នែកសេដ្ឋកិច្ចកាន់តែច្រើនឡើង។ ឆ្នាំ២០១៤ គឺជាឆ្នាំដែលមានអាកាសធាតុក្តៅបំផុតដែលមិនធ្លាប់មានពីមុន ជាមួយបាតុភូតធាតុអាកាសហួសប្រមាណប្រហែល

៩០០ករណី ដែលបណ្តាលឲ្យមានការបាត់បង់ផ្នែកសេដ្ឋកិច្ចគិតជាប្រាក់ចំនួន ១០០ ពាន់លានដុល្លារ។ នេះបើយោងតាមទិន្នន័យរបស់ក្រុមហ៊ុនធានារ៉ាប់រង។[2]

**៣.** ជម្រើសក្រៅពីការដុតឥន្ធនៈហ្វូស៊ីលកាន់តែមានលក្ខណៈល្អប្រសើរ ។ ជោគជ័យនៃថាមពលកកើតឡើងវិញមានលក្ខណៈធំសម្បើម ពោលគឺ ថាមពលពន្លឺព្រះអាទិត្យមានតម្លៃថោក ៨០% និងមានប្រសិទ្ធភាព ៩០% ជាងក្នុងឆ្នាំ ២០០៩។ ថាមពលកកើតឡើងវិញបានក្លាយជាអាជីវកម្ម ដោយសារការចុះតម្លៃដ៏លឿន និងលក្ខខណ្ឌក្របខ័ណ្ឌអំណោយផល ដូចជាច្បាប់ស្តីពីការបញ្ចូលថាមពលកកើតឡើងវិញទៅក្នុងបណ្តាញលក់ថាមពលអគ្គិសនីនៅតាមបណ្តាប្រទេសជាច្រើន។ យោងតាមទីភ្នាក់ងារថាមពលអន្តរជាតិ ថាមពលកកើតឡើងវិញនឹងក្លាយជាប្រភពថាមពលចម្បងមួយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខនេះ។

**៤.** ការវិនិយោគលើថាមពលបៃតង កំពុងកើនឡើង។ ខណៈពេលដែលការវិនិយោគលើឥន្ធនៈហ្វូស៊ីល កាន់តែត្រូវបានគេចាត់ទុកថាមានលក្ខណៈប្រថុយប្រថាន ឬ រហូតដល់ជាទ្រព្យជាប់គាំង ក៏មានការផ្លាស់ប្តូរសំខាន់ៗឆ្ពោះទៅកាន់ថាមពលកកើតឡើងវិញ។ ក្នុងឆ្នាំ ២០១៤ ការវិនិយោគលើថាមពលកកើតឡើងវិញបានកើនឡើង ១៦% ស្មើនឹងទឹកប្រាក់ជាង ៣០០ ពាន់លានដុល្លារ។[3]

**៥.** មតិសាធារណៈកំពុងផ្លាស់ប្តូរ៖ ការប្រែប្រួលអាកាសធាតុកំពុងត្រូវបានចាត់ទុកថាជាការគម្រាមកំហែងមួយចំពោះអនាគតរបស់យើង ខណៈពេលដែលថាមពលកកើតឡើងវិញ ទំនងជាកាលានុវត្តភាពសេដ្ឋកិច្ចមួយ។ កង្វល់កាន់តែកើនឡើងអំពីអនាគតនៃមនុស្សជាតិ កំពុងជំរុញកាន់តែខ្លាំងឡើងឲ្យបណ្តាមេដឹកនាំពិភពលោក រួមទាំងផ្នែកសេដ្ឋកិច្ច សាសនា វិទ្យាសាស្ត្រ សិល្បៈ និងវិស័យដទៃទៀត គិតគូរពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច វិទ្យាសាស្ត្រ កិរិយាមាយាទសង្គម និងសីលធម៌នៃការប្រែប្រួលអាកាសធាតុ។

**៦.** មានសញ្ញាណមុតមាំថា និន្នាការដ៏ធំនៃការកាត់បន្ថយសារធាតុកាបូន បានចាប់ផ្តើមជាសកលៈ ក្រោយពេលរាប់ទសវត្សរ៍ នៃកំណើនជាបន្តបន្ទាប់ និងខ្លាំងក្លានៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និន្នាការនេះហាក់បីដូចជាបាននៅទ្រឹងតាំងពីឆ្នាំ ២០១២ ។ ឆ្នាំ ២០១៤ អាចក្លាយជាឆ្នាំទីមួយជាមួយការបញ្ចេញឧស្ម័នទាបជាងបន្តិច ពីវិស័យថាមពល។[4] រាល់បណ្តាប្រទេសនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ទាំងអស់ បានចាប់ផ្តើមកាត់បន្ថយសារធាតុកាបូន

---

[2] សូមមើល http://www.munichre.com/natcatservice

[3] គំនិតផ្តួចផ្តើមគោលនយោបាយអាកាសធាតុ (ឆ្នាំ ២០១៤)៖ ទិដ្ឋភាពពិភពលោកនៃហិរញ្ញវត្ថុអាកាសធាតុ ឆ្នាំ ២០១៤។

[4] http://www.iea.org/newsroomandevents/news/2015/march/global-energy-related-emissions-of-carbon-dioxide-stalled-in-2014.html

របស់ខ្លួន ហើយប្រទេសចិន ដែលជារដ្ឋភាគីធំបំផុតក្នុងអន្តរកាល ហាក់បីដូចជាកំពុងអនុវត្តដូច្នោះដែរ។[5] ឆ្នាំដែលជាកម្រិតកំពូលពិភពលោកនៃការបញ្ចេញឧស្ម័នជិតឈានដល់។

**៧.** ឆន្ទៈនយោបាយនៃរដ្ឋសមាជិកភាគច្រើន ត្រូវបានផ្តល់ ដើម្បីសម្រេចបានកិច្ចព្រមព្រៀងក្រុងប៉ារីសមួយ៖ ការវិវត្តដែលបានលើកឡើងខាងលើទាំងនេះ បានធ្វើឲ្យក្រុមប្រទេសឧស្សាហូបនីយកម្មធំៗទាំង ៧ (G7) មានជំនឿជាក់ក្នុងការសន្យាកាត់បន្ថយសារធាតុកាបូនក្នុងកិច្ចប្រជុំកំពូលរបស់ខ្លួនក្នុងខែ មិថុនា ឆ្នាំ២០១៥ នៅប្រទេសអាល្លឺម៉ង់។ គិតមកដល់ត្រឹមថ្ងៃទី ២២ ខែ កក្កដា នេះ ប្រទេសចិន សហភាពអឺរ៉ុប សហរដ្ឋអាមេរិក ក៏ដូចជាប្រទេសចំនួន ១៧ ផ្សេងទៀត បានបង្ហាញ INDCs របស់ពួកគេ ហើយប្រទេសជាច្រើនផ្សេងទៀតនឹងធ្វើតាម។ ចំណុចនេះ ពិតជាប្រែក្លាយទៅជាថាមពលថ្មីមួយ និងជាការទម្លុះភាពជាប់គាំងនៅក្នុងការចរចារអាកាសធាតុ។

ការផ្លាស់ប្តូរអាចបន្តប្រឈមមុខនឹងការធាក់ថយក្រោយ ប៉ុន្តែដំណើរការស្វែងរកដំណោះស្រាយយ៉ាងម៉ឺងម៉ាត់មួយទប់ទល់នឹងការគម្រាមកំហែងនៃការប្រែប្រួលអាកាសធាតុ គឺកំពុងបោះជំហានទៅមុខ។

[5] http://energydesk.greenpeace.org/2015/05/14/china-coal-consumption-drops-further-carbon-emissions-set-to-fall-by-equivalent-of-uk-total-in-one-year/

# វិធីសាស្ត្រ

ឯកសារសង្ខេបគោលនយោបាយអាកាសធាតុនេះ បានរៀបរៀងតាមសំណើរបស់ អង្គការមិនមែនរដ្ឋាភិបាលមួយក្រុម ដែលសម្របសម្រួលដោយអង្គការជំនួយរបស់វិហារដាណឺម៉ាក (DCA/CA) និងសហការជាមួយក្រសួងបរិស្ថាន និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia)។ អង្គការ DCA និង CA គឺជាសមាជិកនៃសម្ព័ន្ធភាព ACT (ACT Alliance) ដែលជាសម្ព័ន្ធភាពនៃព្រះវិហារគ្រិស្តចំនួនជាង ១៤០ និងជាអង្គការអភិវឌ្ឍន៍ និងផ្តល់ជំនួយមនុស្សធម៌ ។ សម្ព័ន្ធភាពនេះ ផ្តោតលើសេចក្តីត្រូវការ និងសិទ្ធិរបស់ប្រជាជនក្រីក្របំផុតនៃពិភពលោក និងគាំទ្រការផ្លាស់ប្តូរប្រកបដោយសមធម៌នៃសេដ្ឋកិច្ច និងសង្គម ឆ្ពោះទៅកាន់និរន្តរភាព ការអភិវឌ្ឍដែលបញ្ចេញកាបូនទាប និងភាពធន់នឹងអាកាសធាតុសម្រាប់ទាំងអស់គ្នា។

អ្នកនិពន្ធ បានរៀបរៀងឯកសារសង្ខេបគោលនយោបាយនេះ ជាប្រាំជំហានដូចខាងក្រោម៖

នៅក្នុងជំហានទីមួយ ពួកគេបានសិក្សាឯកសារពាក់ព័ន្ធនានា ដូចជាយុទ្ធសាស្ត្រប្រចាំប្រទេស ជំហរ ឯកសារច្បាប់ និងឯកសារផ្សេងៗទៀត ដើម្បីស្វែងយល់ពីជំហរបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល ឆ្ពោះទៅកាន់គោលនយោបាយអន្តរជាតិស្តីពីអាកាសធាតុ អាទិភាពរបស់កម្ពុជា ចំណុចជាក់លាក់ និងចំណុចខ្វះខាត តាមរយៈការអានឯកសារ។ ក្រៅពីឯកសារនៅក្នុងប្រទេសកម្ពុជា ការសិក្សានេះ ក៏ផ្តោតលើឯកសារសំខាន់ៗនៃក្រុមប្រទេស LDC និងឯកសារពីសម្ព័ន្ធភាព ACT (ACT Alliance) ដែលជាក្រុមសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល ទាក់ទិននឹងគោលនយោបាយអាកាសធាតុអន្តរជាតិ។ បញ្ជីឯកសារយោងត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ។

ជំហានទីពីរ គឺការពិភាក្សាជាក្រុម និងការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ តាមការស្នើរបស់ម្ចាស់កិច្ចសន្យា ដើម្បីបង្កើនការយល់ដឹងបន្ថែមទៀតអំពីការរំពឹងទុក និងទស្សនៈយោបល់អំពីក្រុងប៉ារីសនៃភាគីពាក់ព័ន្ធទាំងនេះ។ រាល់បទសម្ភាសន៍ទាំងអស់ ឧទាហរណ៍ ជាមួយតំណាងពីក្រសួងបរិស្ថាន ស្ថាប័នសហប្រជាជាតិ និងសង្គមស៊ីវិល ត្រូវចងក្រងជាឯកសារ និងអាចស្វែងរកបាននៅក្នុងឧបសម្ព័ន្ធ។

នៅក្នុងជំហានទីបី គឺសិក្សាអំពីស្ថានភាពបច្ចុប្បន្ននៃការចរចារ សេណារីយ៉ូសម្រាប់ក្រុងប៉ារីស និងជំហររបស់តួអង្គសំខាន់ៗ ដោយយកចិត្តទុកដាក់ដោយឡែកលើបញ្ហា និងចំណុចសំខាន់ៗមួយចំនួន ដែលជាអាទិភាពគន្លឹះរបស់សង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា។ ប្រការនេះ បាននាំទៅដល់ការបង្កើតជម្រើសគោលនយោបាយមួយចំនួន ដែលឆ្លុះបញ្ចាំង ជាអាទិ៍ នូវសំណួរដូចតទៅ៖

តើនៅមានគោលនយោបាយអ្វីខ្លះដែលនៅសេសសល់ សំរាប់រយៈពេលបួនខែ មុនសន្និសីទក្រុងប៉ារីស? តើលទ្ធផលដែលកំណត់ជាមុនរួចស្រេចបានកម្រិតណា? តើក្រុងប៉ារីសមានចំណុចសំខាន់ៗអ្វីខ្លះដែលត្រូវដាក់បញ្ចូល? តើវាប្រទាក់ក្រឡាគ្នាយ៉ាងដូចម្តេច? តើអ្វីទៅអាចជាទម្រង់ច្បាប់? តើអ្នកណាខ្លះអាចជាដៃគូសម្ព័ន្ធមិត្តសម្រាប់ប្រទេសកម្ពុជា? តើបញ្ហារសើបមានអ្វីខ្លះ? តើអ្នកណាខ្លះគឺជាដៃគូដែលមានគំនិតខ្វែងគ្នា? តើចំណុចរួមអាចមានអ្វីខ្លះ និងថាតើកិច្ចព្រមព្រៀងជាកញ្ចប់ រួមទាំងអាទិភាពរបស់កម្ពុជា អាចមានលក្ខណៈដូចម្តេច?

នៅក្នុងជំហានទីបួន អ្នករៀបរៀងបានផ្តល់អនុសាសន៍គោលនយោបាយមួយចំនួន ដែលជាលទ្ធផលពីជំហានទីបី និងដែលសំដៅផ្តល់ការណែនាំ និងជាគំនិតជូនម្ចាស់កិច្ចសន្យា។

នៅក្នុងជំហានចុងក្រោយ សេចក្តីព្រាងឯកសារសង្ខេបគោលនយោបាយ ត្រូវបានពិភាក្សាជាមួយម្ចាស់កិច្ចសន្យា មុននឹងសរសេរបញ្ចប់ និងបង្ហើយជាស្ថាពរ។

ប្រភពឯកសារនៅក្នុងការសិក្សានេះ ត្រូវបានផ្តល់តាមរយៈលេខយោង និងឯកសារយោងក្នុងឧបសម្ព័ន្ធ។

## លទ្ធផល និងសេចក្តីសន្និដ្ឋានស្តីពីស្ថានភាពនៃកិច្ចពិភាក្សាអំពីអាកាសធាតុ

## ដំណើរការអន្តរជាតិដែលនាំទៅដល់កិច្ចព្រមព្រៀងក្រុងប៉ារីស

វាគឺការជឿជាក់ដ៏រឹងមាំរបស់ប្រធានក្នុងអាណត្តិថ្មី និង អាណត្តិចាស់នៃ COP ពោលគឺ ប្រទេសបារាំងនិងប៉េរូ ក៏ដូចជាលេខាធិការដ្ឋាន UNFCCC និងភាគីសំខាន់ៗ ដើម្បីសម្រេចបានកិច្ចព្រមព្រៀងលើចំណុចសំខាន់ៗ ដែលនឹងជាលទ្ធផលនៃក្រុងប៉ារីស ទាំងខ្លឹមសារ និងទម្រង់នៃកិច្ចព្រមព្រៀង ឲ្យបានមុន COP២១ ក្នុង ខែធ្នូ។ ទស្សនៈនេះ ក៏មានលក្ខណៈស្របគ្នាផងដែរជាមួយសេចក្តីសម្រេចរបស់ COP លើកមុន ដែលព្យាករណ៍ថា សេចក្តីព្រាងច្បាប់ដែលសមស្របសម្រាប់ការចរចារចុងក្រោយ គប្បីត្រៀមឲ្យបានស្រេច មិនឲ្យហួសពីខែឧសភា ឆ្នាំ២០១៥ ។ សេចក្តីព្រាងអត្ថបទសម្រាប់កិច្ចចរចារត្រូវបានរៀបរៀងរួចហើយក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ប៉ុន្តែវានៅតែស្ថិតនៅឆ្ងាយពីចំណុចដែលឈានទៅដល់ការចរចារបាន។

ភាគីភាគច្រើនឯកភាពថា សេណារីយ៉ូក្រុងកូប៉េនហាកមួយទៀត គប្បីត្រូវជៀសវាង ដែលពេលនោះសេចក្តីសម្រេចត្រូវបានធ្វើនៅនាទីចុងក្រោយដោយប្រទេសមួយក្រុមតូច។ ជារួមបណ្តាប្រទេសទាំងអស់ដែលមានគោលបំណងសម្រេចបានលទ្ធផលប្រកបដោយមហិច្ឆតាមួយ ប៉ុន្តែដោយឡែក បណ្តាប្រទេសតូចតាច និងងាយរងគ្រោះពីអាកាសធាតុ ដូចជាប្រទេស LDC និង SIDS ជាដើម ដែលនៅក្នុងនោះ SIDS ដែលបានរួបរួមគ្នា AOSIS ទទូចសុំឲ្យមាន ដំណើរការចរចារមួយដែលផ្តល់សិទ្ធិដល់គ្រប់ប្រទេសដែលជាសមាជិក និងមានការចូលរួមពេញលេញ ដែលនៅក្នុងនោះសេចក្តីសម្រេចត្រូវតែធ្វើរួមគ្នា។ ពួកគេប្រឆាំងដាច់ខាតចំពោះការសម្រេចអ្វីមួយនៅនាទីចុងក្រោយ ដែលមានតែប្រទេសមានអំណាចមួយចំនួនតូចប៉ុណ្ណោះ និង ផ្អែកតែទៅលើការយល់ព្រមតិចតួចបំផុត ដែលបានចែងតែនៅលើក្រដាសក្នុងទម្រង់មួយដែលមិនត្រូវបានរៀបចំពីគ្រប់ភាគីទាំងអស់ ឬ មិនត្រូវបានពិភាក្សា និងឯកភាពនៅក្នុងការស្រុះស្រួលគ្នា ហើយជាចុងក្រោយ មិនបានផ្តល់ជម្រើសអ្វីផ្សេងទៀតឲ្យប្រទេសភាគច្រើនលើសលុបចុះហត្ថលេខា ឬ ចាកចេញពីក្រុងប៉ារីសដោយគ្មានកិច្ចព្រមព្រៀងអ្វីមួយ។ ភាគីទាំងឡាយដែលបានប្រកាន់យកជំហរនោះ គប្បីចាប់យកសម័យប្រជុំក្រុមការងារ ADP ដែលចាប់ផ្តើមនៅចុងខែ សីហា ឆ្នាំ ២០១៤ ហើយវាជាឱកាសចុងក្រោយ ដើម្បីជំរុញការចរចារបច្ចុប្បន្នឆ្ពោះទៅមុខ។ ភាគីដទៃទៀតដែលមិនសូវ ឬមិនចាប់អារម្មណ៍លើការសម្រេចបានកិច្ចព្រមព្រៀងប្រកបដោយមហិច្ឆតា ទោះបីបានតែវោហារសាស្ត្រក្តី អាចបន្តបង្អាក់ដំណើរ និងពន្យារដំណើរការចរចារដែរ ដែលជាលទ្ធផល នឹងធ្វើឲ្យគេមិនអាចឯកភាពគ្នាលើលទ្ធផលសំខាន់ៗ។ ភាគីខ្លះនៃភាគីទាំងនោះ ដែលមានជំនឿជាក់ថានឹងស្ថិតនៅក្នុងចំណោមក្រុមតូច ដែលជាចុងក្រោយអាចនឹងព្យាយាមសម្រេចឲ្យបាននូវការឯកភាពគ្នាមួយនៅ

នាទីចុងក្រោយ នៅខាងក្រោយទ្វាបិទ ក៏មិនសូវខ្វល់ផងទេ អំពីវឌ្ឍនភាពយឺតដែលសម្រេចបាន គិតមកដល់ពេលនេះ។ ប្រាកដណាស់ប្រទេសកម្ពុជា ពិតជាស្ថិតនៅក្នុងក្រុមទីមួយ និងធំជាងគេបំផុតនៃបណ្តាប្រទេស ដែលមានចំណាប់អារម្មណ៍ច្រើន លើការងារឆ្ពោះទៅរកបៀបចរចារប្រកបដោយអត្ថន័យមួយ។

កិច្ចប្រជុំ ADP ខាងមុខ ដែលបច្ចុប្បន្នត្រូវបានគ្រោងធ្វើនៅថ្ងៃទី ៣១ ខែសីហា ដល់ថ្ងៃទី ៤ ខែកញ្ញា ជាមួយជម្រើសពន្យារពេលពីរបីថ្ងៃ ប្រហែលជានឹងផ្តល់ឱកាសចុងក្រោយ ដើម្បីប្រែក្លាយអត្ថបទចរចារឲ្យក្លាយទៅជាឯកសារមួយ ដែលមានលក្ខណៈសង្ខេបខ្លី និងអាចរៀបចំបានល្អជាមុន ដោយមានសេចក្តីព្រាងមួយ ដើម្បីជួយដល់ ការធ្វើសេចក្តីសម្រេច នៅទីក្រុងប៉ារីស ចំពោះបញ្ហាដែលនៅសេសសល់មិនបានដាក់បញ្ចូល នៅក្នុងកិច្ចព្រមព្រៀងស្អូល។

ក្នុងការរៀបចំកិច្ចប្រជុំនេះ កិច្ចប្រជុំក្រៅផ្លូវការថ្នាក់រដ្ឋមន្ត្រីមួយបានប្រព្រឹត្តទៅនៅក្រុង**លុចហ្សំបួ** នៅថ្ងៃទី ១៨ – ១៩ ខែកក្កដា ដោយមានការចូលរួមពីរដ្ឋមន្ត្រីប្រហែលសែសិបនាក់ ក្នុងនោះរួមមានតំណាងពីគ្រប់ភាគីសំខាន់ៗ និងក្រុមប្រទេស ដែលត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីការបរទេសបារាំង លោក **ហ្វាប៊្យូស** (Fabius)។ នៅថ្ងៃទី ២៤ ខែកក្កដា សហប្រធាន ADP បច្ចុប្បន្នទាំងពីរ គឺលោក **អាម៉េដ ចូឡាហ្វ** (Ahmed Djoghlaf) នៃប្រទេសអាល់ហ្សេរី និងលោក **ដានីញ៉ែល រ៉េហ្វស្នាយ-ឌ័រ** (Daniel Reifsnyder) នៃសហរដ្ឋអាមេរិក បានប្រកាសថានឹងផ្សព្វផ្សាយឯកសារចរចារមួយដែលមានលក្ខណៈច្បាស់លាស់ សង្ខេបខ្លី និងបញ្ចូលគ្រប់សំណើរពីបណ្តារដ្ឋជាសមាជិក សម្រាប់កិច្ចប្រជុំ ADP ខាងមុខ។

បច្ចុប្បន្ន គេឃើញមានសេណារីយ៉ូសំខាន់ពីរសម្រាប់ជំហានខាងមុខៈ

(១) ប្រសិនបើភាគីដែលទទួលបានផលប្រយោជន៍ច្រើនជាមួយការចរចារក្នុងកិច្ចប្រជុំ ADP នាខែសីហា/កញ្ញា មានន័យថា វាពិតជាមានការចាប់ផ្តើមការចរចារ ឯកភាពលើអ្វីដែលអាចឯកភាពគ្នាកាត់បន្ថយជម្រើស និងពិភាក្សារកចំណុចរួម ដែលអាចមានការយល់ស្របគ្នា ចំពោះបញ្ហាចម្រូងចម្រាស់ នោះពួកគេអាចមានឱកាសឯកភាពគ្នាលើសមាសភាគសំខាន់ៗនៅក្នុងកិច្ចប្រជុំប្រធានរដ្ឋទន្ទឹមគ្នាមហាសន្និបាតសហប្រជាជាតិក្នុង ខែកញ្ញា និងសម្រេចបាននូវសេចក្តីព្រាងមួយសម្រាប់កិច្ចព្រមព្រៀងក្រុងប៉ារីសនៅក្នុងកិច្ចប្រជុំ ADP ចុងក្រោយ (ថ្ងៃទី ១៩ – ២៣ ខែតុលា)។ បន្ទាប់មកទៀត វានឹងអាចមានកិច្ចប្រជុំមួយទៀត ថ្នាក់រដ្ឋមន្ត្រី ។

(២) ប្រសិនបើភាគីដែលមិនបានទទួលជោគជ័យក្នុងខែ សីហា/កញ្ញា ទេនោះ ឯកសារចរចារបច្ចុប្បន្ន ដែលមានឈ្មោះថា "**ឯកសារក្រុងហ្សឺណែវ**" ទំនងជានឹងមានលក្ខណៈស្លាប់ខាង

នយោបាយ និងត្រូវជំនួសដោយឯកសារថ្មីមួយ ដែលត្រូវបានផ្តល់ដោយប្រធាន COP មុនពេលកិច្ចប្រជុំប្រធានរដ្ឋ ដែលត្រូវរៀបចំឡើងនៅខែកញ្ញា។ ប្រសិនបើការចរចារបន្តជាមួយ "ឯកសារចម្លែក" មួយបែបនេះ ភាពចូលរួមពេញលេញនៃការធ្វើសេចក្តីសម្រេចនឹងត្រូវបានកាត់បន្ថយយ៉ាងច្រើន ហើយលទ្ធភាពសម្រេចបានអាទិភាពជាច្រើនតាមដែលអាចធ្វើទៅបានរបស់កម្ពុជា និងបណ្តាប្រទេសអភិវឌ្ឍតិចតួច គឺទំនងជានឹងថយចុះ។ ដោយអាស្រ័យលើការទទួលយកនូវសេចក្តីព្រាងថ្មីមួយរបស់ប្រធានកិច្ចប្រជុំដោយចូលរួមពីភាគីសមាជិកនោះកិច្ចព្រមព្រៀងគន្លឹះនៅតែអាចសម្រេចបានមុន COP២១ ឬ អ្វីដែលទំនងជានឹងកើតឡើងនោះ គឺជាសេចក្តីសម្រេចមួយនៅនាទីចុងក្រោយនៃបណ្តាប្រទេសមួយក្រុមតូចដែលមានឥទ្ធិពលនៅក្នុងសន្និសីទក្រុងប៉ារីស។បមិនដូច្នោះទេ ការសម្រេចអាចជាប្រធាន COP នៃប្រទេសបារាំង ប្រទេសចិន សហរដ្ឋអាមេរិក និងបណ្តាប្រទេសដទៃទៀតមួយក្តាប់តូចតែប៉ុណ្ណោះ។

ប្រការសំខាន់ គឺត្រូវយល់ថានៅក្នុងសេណារីយ៉ូទាំងពីរ សេចក្តីសម្រេចគន្លឹះនឹងត្រូវរៀបចំទុកមុនពេលដំណើរការ COP និងប្រហែលជាយ៉ាងហោចណាស់ក៏មួយផ្នែកដែរ នៅក្រៅកិច្ចដំណើរ UNFCCC ការផ្លូវការ។ ទស្សនៈរួមខាងក្រោម គូសបង្ហាញពីកិច្ចប្រជុំកំពូលអន្តរជាតិ ដែលមានលក្ខណៈសមស្របក្នុងបរិបទនេះ។ ក្រៅពីនេះ ការពិគ្រោះយោបល់ក្រៅផ្លូវការជាហូរហែរ ត្រូវបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហារសើប និងឯកភាពលើសមាសភាគស្នូលនៃលទ្ធផលក្រុងប៉ារីស។

**ហិរញ្ញប្បទានសហប្រជាជាតិសម្រាប់កិច្ចប្រជុំអភិវឌ្ឍន៍កំពូលនៅក្រុងអាឌីស** ថ្ងៃទី ១៣ – ១៥ ខែកក្កដា បានស្ថាបនាគ្រឹះមួយសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ហិរញ្ញវត្ថុ នៅក្នុងបណ្តាឆ្នាំខាងមុខ។ វាមានលក្ខណៈសមស្របក្នុងការគ្រោងការចរចារស្តីពីហិរញ្ញប្បទានអាកាសធាតុរយៈពេលវែង ប៉ុន្តែ មានពន្លឺបន្តិចបន្តួចប៉ុណ្ណោះលើតួនាទីអនាគតនៃរដ្ឋថ្មីក្នុងអន្តរកាលដូចជាប្រទេសចិន សាអូឌី អារ៉ាប៊ី សឹង្ហបុរី កាតារ ម៉ិកស៊ិក្ខ និង ប្រទេសដទៃទៀត។

**កិច្ចប្រជុំកំពូលសហប្រជាជាតិស្តីពីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្រុងញូវយ៉ក**, ថ្ងៃទី ២៥ -២៧ ខែ កញ្ញា ត្រូវបានរំពឹងថានឹងសម្រេចបានរបៀបវារៈអភិវឌ្ឍន៍ថ្មីមួយក្រោយឆ្នាំ ២០១៥ ជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលជំនួសគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)។ ការប្រែប្រួលអាកាសធាតុ ការជំរុញភាពធន់ និង ការផ្តល់ថាមពលប្រកបដោយនិរន្តរភាព គឺជាបញ្ហានៅក្នុងរបៀបវារៈនៃចរចារ។ កិច្ចប្រជុំកំពូលនេះ នឹងបំភ្លឺបន្ថែមទៀតថាតើប្រទេសនឹងពិតជាតាំងចិត្តដល់កម្រិតណាក្នុងការផ្លាស់ប្តូរទៅកាន់គំរូនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ វាក៏នឹងគ្រោងផងដែរនូវការសន្ទនាអំពីរបៀបបែងចែករវាងប្រទេសនាអនាគត និង ការវិវត្តនៃការទទួលខុសត្រូវនិងលទ្ធភាពរបស់ពួកគេ ពាក់ព័ន្ធនឹងការចែករំលែកកិច្ចប្រឹងប្រែង និង ការសន្យាថ្នាក់ជាតិ។

**កិច្ចប្រជុំកំពូលនៃក្រុមប្រទេស ២០ (G20) នៅក្រុងអាតាលីយ៉ា ប្រទេសទួគី**, ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១៥ - ១៧ ខែ វិច្ឆិកា ផ្តល់ឱកាសចុងក្រោយសម្រាប់ឲ្យប្រធានរដ្ឋនៃក្រុមប្រទេស ២០ (G20) បានជួបគ្នាមុន COP នាក្រុងប៉ារីស។ ទោះបីជាបញ្ហាអាកាសធាតុ ជាធម្មតា មិនត្រូវបានកំណត់ជាអាទិភាពនៅក្នុងកិច្ចប្រជុំនៃក្រុមប្រទេស ២០ (G20) ក្តី ក៏ហិរញ្ញប្បទានអាកាសធាតុ ក៏ដូចជាលទ្ធភាពកែលម្អចំពោះការប្រើប្រាស់ថាមពលកកើតឡើងវិញ និង កាត់បន្ថយជាបណ្តើរៗនូវឧបត្ថម្ភធនឥន្ធនៈហ្វូស៊ីល ស្ថិតនៅក្នុងរបៀបវារៈដែរ។ ការសន្យាដ៏មុតមាំរបស់ក្រុមប្រទេស ២០ (G20) ចំពោះលទ្ធផលប្រកបដោយអត្ថន័យនៃកិច្ចព្រមព្រៀងក្រុងប៉ារីស ដែលត្រូវបានកំណត់នៅក្នុងសេចក្តីប្រកាសរបស់ក្រុមប្រទេស ២០ (G20) នឹងផ្តល់សញ្ញាដ៏ខ្លាំងមួយឆ្ពោះទៅកាន់សន្និសីទក្រុងប៉ារីស។ ក្រុមប្រទេសសេដ្ឋកិច្ចទាំង ២០ (G20) ទទួលខុសត្រូវលើ ៧៥% នៃការបញ្ចេញឧស្ម័នពិភពលោក។ មហិច្ឆតាអាកាសធាតុរបស់ពួកគេ គឺជាឆ្អឹងខ្នងនៃកិច្ចព្រមព្រៀងក្រុងប៉ារីស។

## ឯកសារចរចារបច្ចុប្បន្ន និង សមាសភាគគន្លឹះទាំងឡាយ

ដូចមានក្នុងឯកសារនៃលទ្ធផល COP២០ នៅក្រុងលីម៉ា ក្នុងខែ ធ្នូ ឆ្នាំ ២០១៥ ដែរ អ្វីដែលគេហៅថា "សមាសភាគនៃសេចក្តីព្រាងឯកសារចរចារមួយ" ត្រូវបានឯកភាពគ្នានៅក្នុងសេចក្តីសម្រេចលេខ COP២០/១។ ឯកសារនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធមាន ៣៩ ទំព័រទៅនឹង "ការអំពាវនាវឲ្យមានសកម្មភាពនៃក្រុងលីម៉ា"។[6]

ឯកសារនេះ បានបំពេញមុខងារជាមូលដ្ឋានសម្រាប់ការចរចារបន្ថែមទៀត នៅក្នុងកិច្ចប្រជុំ ADP ទី១ក្នុងឆ្នាំ ២០១៥ ដែលបានប្រព្រឹត្តទៅនៅក្រុងហ្សឺណែវក្នុងខែ កុម្ភៈ។ ឯកសារនេះ ត្រូវបានពង្រីកបន្ថែមទៀតរហូតដល់ ៨៦ ទំព័រ និង ត្រូវបានអនុម័តជាចុងក្រោយជាឯកសារចរចារក្រុងប៉ារីសផ្លូវការ។[7]

ក្នុងសម័យប្រជុំ ADP ២.៩ ក្នុងខែ មិថុនា ឆ្នាំ ២០១៥ នៅក្រុងបោន ឯកសារនេះ ត្រូវបានពិភាក្សា និងកែសម្រួល ជាថ្មីម្តងទៀត។ វាបានក្លាយជាឯកសារមួយដែលមាន ៨៥ ទំព័រ។[8] ទោះបីជាមានកិច្ចប្រជុំក្រុមការងាររហូតដល់ ៧៥ ដង ដែលត្រូវបានរៀបចំស្របតាមផ្នែកទាំងឡាយនៃឯកសារនេះ និង ដែលត្រូវបានដឹកនាំដោយអ្នកសម្របសម្រួលបន្តគ្នាក្តី[9] ក៏នៅពេលចប់សម័យប្រជុំនាខែមិថុនា ចុងក្រោយនេះ ភាគីបានឯកភាពទទួលយកសំណើរបស់សហប្រធាន ADP[10] និង បានកំណត់ឲ្យសហប្រធានបង្ហាញឲ្យបានមុនថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ នូវកំណែឯកសារខ្លីនិង

[6] https://unfccc.int/files/meetings/lima_dec_2014/application/pdf/auv_cop20_lima_call_for_climate_action.pdf
[7] https://unfccc.int/files/bodies/awg/application/pdf/negotiating_text_12022015@2200.pdf
[8] http://unfccc.int/files/bodies/awg/application/pdf/adp2-9_i3_11jun2015t1630_np.pdf
[9] http://unfccc.int/files/bodies/awg/application/pdf/updated_information_on_facilitators_and_co-facilitators.pdf
[10] https://unfccc.int/files/bodies/awg/application/pdf/way_forward_11_june_-_edits_1026am.pdf

រលូនមួយទៀតដែលនឹងមិនមានលុបជម្រើសណាមួយទេ ប៉ុន្តែ ត្រូវកែសំរួល/សម្អាតជម្រើសទាំងនេះ តាមវិធីមួយដែលធ្វើឲ្យការចរចារពិតប្រាកដអាចចាប់ផ្តើមនៅក្នុងសម័យប្រជុំ ADP ខាងមុខ។ ប៉ុន្តែ កំណែឯកសារក្រុងហ្សឺណែវនឹងនៅតែគឺជាឯកសារចរចារផ្លូវការតែមួយគិតរហូតដល់ពេលដែល COP សម្រេចជំនួសឯកសារនេះដោយកំណែថ្មីមួយ។

ឯកសារនេះ ត្រូវបានរៀបចំជាផ្នែកតាមប្រធានបទ និង បន្ថែមលើចំណុចសំខាន់ៗ និង ក្រៅពីអារម្ភកថា រួមមាននិយមន័យ គោលបំណងទូទៅ ជំពូកស្តីពីការកាត់បន្ថយហេតុ ការបន្សាំ និង ការបាត់បង់ និងការខូចខាត ហិរញ្ញវត្ថុ ការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព តម្លាភាពនៃសកម្មភាពនិងការគាំទ្រ ក្របខ័ណ្ឌពេលវេលា និង បញ្ហានីតិវិធី និង ការជួយសម្រួលការអនុវត្តនិង អនុលោមភាព។ វាគឺជាប្រការសំខាន់ ដែលត្រូវកត់សម្គាល់ថាជំពូកនីមួយៗ រួមមានជម្រើសផ្សេងៗ និង ភាគច្រើនផ្ទុយគ្នាជាច្រើនសន្ទឹក ដែលតំណាងឲ្យទស្សនៈផ្សេងៗគ្នាទាំងអស់នៃភាគី។ ហេតុដូច្នេះ ឯកសារនេះនៅឆ្ងាយពីភាពអាចចរចារបាន និង មិនទាន់ត្រូវបានព្រាងក្នុងទម្រង់ខ្លឹមួយដែលចាំបាច់សម្រាប់កិច្ចព្រមព្រៀងអន្តរជាតិឡើយ។ លើសពីនេះ ឯកសារក្រុងហ្សឺណែវនេះ មិនមាន ផ្តល់សំណើអ្វីសម្រាប់ទម្រង់ច្បាប់នៃសមាសភាគផ្សេងៗនៃឯកសារទេ ពោលគឺ កិច្ចព្រមព្រៀងស្នូល សេចក្តីសម្រេច COP សេចក្តីប្រកាសនយោបាយ ឬ ទម្រង់អ្វីផ្សេងទៀតឡើយ។ កង្វះវឌ្ឍនភាពទាក់ទិននឹងឯកសារនេះ ធ្វើឲ្យជំនាញការផ្នែកច្បាប់មានកង្វល់ច្រើន។ ពួកគេអះអាងថាកិច្ចដំណើរការចរចារយឺតយ៉ាវអស់ពេល ១-៣ ឆ្នាំ នៅក្រោយការកំណត់ពេលគ្រប់គ្រាន់សម្រាប់កិច្ចព្រមព្រៀងអន្តរជាតិដ៏ទូលំទូលាយមួយប្រកបដោយមហិច្ឆតាដូចកិច្ចព្រមព្រៀង ដែលគេរំពឹងទុកនៅប៉ារីស។

## លទ្ធភាពស្ថាបត្យកម្មនិងទម្រង់ច្បាប់នៃកិច្ចព្រមព្រៀងក្រុងប៉ារីស

ដើម្បីទទួលបានជោគជ័យនៅប៉ារីស កិច្ចព្រមព្រៀងលើទម្រង់ច្បាប់នៃសមាសភាគនីមួយៗ និងកន្លែងដែលត្រូវដាក់កិច្ចព្រមព្រៀងទាំងនេះជាផ្លូវការនៅក្នុងកញ្ចប់ក្រុងប៉ារីស គឺជាការចាំបាច់។ ចំពោះស្ថាបត្យកម្មនៃកិច្ចព្រមព្រៀងកញ្ចប់នេះត្រូវបានរំពឹងថាមានក្នុងស្រទាប់៖ កិច្ចព្រមព្រៀងស្នូលមួយ (អាចមានឧបសម្ព័ន្ធមួយ) សេចក្តីសម្រេច COP និងកញ្ចប់សេចក្តីប្រកាសនយោបាយមួយ។

ផ្អែកលើទស្សនៈរបស់ប្រទេស ដែលមានមហិច្ឆតាអាកាសធាតុ កិច្ចព្រមព្រៀងស្នូលស្របច្បាប់គប្បី ត្រូវដាក់ក្រោមអនុសញ្ញា ដែលត្រូវបានគ្រោងឲ្យមានអាត្តិភាពច្រើនទសវត្សរ៍។ កិច្ចព្រមព្រៀងស្នូលនេះ គប្បីពិព័ណ៌នាគោលដៅទូទៅ ឬ គោលបំណងរយៈពេលវែង (ឧទាហរណ៍ រក្សាការឡើងកម្តៅផែនដីឲ្យនៅក្រោម ១.៥°C) ក៏ដូចជា គោលការណ៍និងវិធាននៃកិច្ចព្រមព្រៀងថ្មី (ឧទាហរណ៍

យន្តការមួយ ដែលត្រូវអនុវត្តចំពោះភាគីទាំងអស់ និង ដែលត្រូវបានរៀបចំដើម្បីតាមដាន ពិនិត្យ វាយតម្លៃ និង ជំរុញកិច្ចប្រឹងប្រែងរួម ដែលជាលទ្ធផលបានមកពី INDC ដើម្បីភ្ជិតគម្លាតនៃការបញ្ចេញឧស្ម័ន និង ហានិភ័យអាកាសធាតុ)។ ទិដ្ឋភាពនានាទាក់ទិននឹងគោលការណ៍និងវិធាន ត្រូវបានដាក់បញ្ចូលក្នុងជំពូកផ្សេងៗនៃសេចក្តីព្រាងឯកសារចរចារបច្ចុប្បន្ន រួមទាំងគោលការណ៍និងវិធានស្តីពីតម្លាភាពនៃសកម្មភាពនិងការគាំទ្រ ក្របខ័ណ្ឌពេលវេលា និង ការជួយសម្រួលការអនុវត្ត និង អនុលោមភាព។

កិច្ចព្រមព្រៀងស្នូល អាចត្រូវបានបំពេញបន្ថែមដោយឧបសម្ព័ន្ធបច្ចេកទេសមួយ និង/ឬ និយាយដល់លិខិតូបករណ៍គាំទ្រដែលខ្លឹមសាររបស់វាត្រូវបានសម្រេចនៅថ្នាក់ជាតិ ឧទាហរណ៍ ប្រព័ន្ធចុះបញ្ជីមួយ ឬ ឯកសារព័ត៌មានអំពីការសន្យាដែលបានសម្រេចនៅថ្នាក់ជាតិ។

សេចក្តីសម្រេច COP គប្បីឆ្លើយតបទៅនឹងបញ្ហាដោយឡែកនៅមុននិងក្រោយឆ្នាំ ២០២០ ឲ្យបានកាន់តែលម្អិត ដែលត្រូវអនុម័តនៅ COP ២១ ឬ ក្រោយពេលនោះ។ បញ្ហាទាំងឡាយដែលត្រូវបានដោះស្រាយនៅក្នុងសេចក្តីសម្រេចអាចប្រែប្រួលនៅពេលក្រោយ។

សេចក្តីប្រកាសនយោបាយ គប្បីជួយអនុវត្តកិច្ចព្រមព្រៀងស្នូល និង សេចក្តីសម្រេច COP ដោយជំរុញសកម្មភាពសហការគ្នា ឧទាហរណ៍ តាមរយៈកិច្ចប្រឹងប្រែងបន្ថែមដោយស្ម័គ្រចិត្តដើម្បីបង្កើនមហិច្ឆតាអាកាសធាតុ ឬ ការផ្តល់ការគាំទ្រ។

សមាសភាគប្រធានបទនីមួយៗនៃកញ្ចប់ក្រុងប៉ារីស ត្រូវបានចែកចេញជាសមាសភាគរង ដែលអាចស្ថិតនៅក្នុងស្រទាប់លើសពីមួយនៃស្រទាប់ទាំងបី ។ វាគឺជាប្រការសំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យនយោបាយ ដែលត្រូវធានាឲ្យបានថាកិច្ចព្រមព្រៀង ស្នូលមិនមានដាក់បញ្ចូលឧបសគ្គចំពោះការបង្កើនមហិច្ឆតាអាកាសធាតុ។ អាទិភាពទីពីរ គឺការដាក់បញ្ចូលកាតាលីករឲ្យបានច្រើនតាមដែលអាចធ្វើបានទៅក្នុងកិច្ចព្រមព្រៀង។ សេចក្តីសម្រេច COP មានឋានៈទាបជាងខណៈពេលដែលសេចក្តីប្រកាសនយោបាយមិនត្រូវជំនួសយន្តការច្បាប់មួយឡើយ ប៉ុន្តែអាចជំរុញការអនុវត្តយន្តការច្បាប់។

## អាទិភាពគោលនយោបាយអាកាសធាតុកម្ពុជា

ដោយត្រូវបានចាត់ទុកថា ជាប្រទេសងាយរងគ្រោះបំផុត ពីអាកាសធាតុនៃតំបន់អាស៊ីគ្នេយ៍[11] អាទិភាពកំពូលនៃប្រទេសកម្ពុជា គឺការបង្កើនសមត្ថភាពឆ្លើយតបរបស់ខ្លួនទៅនឹងការប្រែប្រួល

[11] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១០។

អាកាសធាតុ។ វាគឺជាប្រការសំខាន់ ដែលត្រូវកត់សម្គាល់ថា ភាពងាយរងគ្រោះខ្ពស់ក្នុងកម្រិតតិចជាង គឺ បណ្ដាលមកពីការគម្រាមកំហែងនៃអាកាសធាតុហួសហេតុ (គម្រាមកំហែងទាំងនេះមានលក្ខណៈប្រហាក់ប្រហែល ឬ ទាបជាងនៅប្រទេសជិតខាង) ប៉ុន្តែ ផ្ទុយទៅវិញ គឺបណ្ដាលមកពីភាពធន់នៅមានកម្រិតទាបបំផុត និង ភាពផុយស្រួយរបស់ប្រទេសជារួម និង ដោយឡែកប្រជាជនជនបទរបស់ប្រទេស ពឹងផ្អែកភាគច្រើនលើវិស័យកសិកម្ម។ យោងតាមការសិក្សាវិទ្យាសាស្ត្រ និន្នាការបច្ចុប្បន្ននៃការឡើងកម្ដៅ (+ ០,៨°C តាំងពីឆ្នាំ ១៩៦០) អាចបង្កើនល្បឿនយ៉ាងខ្លាំងក្នុងបណ្ដាទសវត្សរ៍ខាងមុខនៅក្នុងអាងទន្លេមេគង្គ ដែលជាហេតុធ្វើឲ្យតំបន់នេះ ក៏ដូចជាការដាំដំណាំស្រូវ និង ការគ្រប់គ្រងទឹកជម្រាលនៃតំបន់នេះ មានហានិភ័យ។ អាស្រ័យហេតុនេះការប្រែប្រួលអាកាសធាតុ កំពុងត្រូវបានគេចាត់ទុកថាជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និង និរន្តរភាពបរិស្ថានរបស់កម្ពុជា។[12] សេដ្ឋកិច្ចដ៏មានមូលដ្ឋានដ៏ចង្អៀតរបស់កម្ពុជាដែលពឹងផ្អែកយ៉ាងខ្លាំង លើវិស័យកសិកម្ម រោងចក្រកាត់ដេរសម្លៀកបំពាក់ និង វិស័យទេសចរណ៍ត្រូវតែមានភាពធន់កាន់តែខ្លាំងឡើង ជាពិសេស វិស័យស្បៀងអាហារ (ដែលគ្របដណ្ដប់ដោយការធ្វើស្រែតូចតាច និង សិប្បកម្មនេសាទ)។

ក្រៅពីការកែលម្អភាពធន់នឹងអាកាសធាតុ កម្ពុជាផ្ដល់អាទិភាពដល់ការកៀរគរសក្ដានុពលថាមពលកកើតឡើងវិញរបស់ខ្លួន ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងលើឥន្ធនៈហ្វូស៊ីល (៩៥% នៃអគ្គិសនី) និង ដើម្បីជំនះកង្វះខាត ថាមពល ដែលត្រូវបានចាត់ទុកថាជាមូលហេតុគន្លឹះមួយនៃកម្រិតឧស្សាហូបនីយកម្មកម្រិតទាប របស់ប្រទេស។[13]

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ឆ្នាំ ២០១៤-២០២៣ បច្ចុប្បន្ន (ផែនការយុទ្ធសាស្ត្រ)[14] គឺជាឯកសារគន្លឹះដែលកំណត់សកម្មភាពនិងយុទ្ធសាស្ត្រជាតិ។ ដោយកសាងលើកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) និង គោលនយោបាយជាតិអភិវឌ្ឍន៍ បៃតង ផែនការយុទ្ធសាស្ត្រនេះ សំដៅដាក់បញ្ចូលយុទ្ធសាស្ត្រឆ្លើយតបនឹងអាកាសធាតុទៅក្នុងកិច្ចដំណើរការរៀបចំផែនការអភិវឌ្ឍន៍ជាតិទូលំទូលាយជាង ពោលគឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ NSDP (ឆ្នាំ ២០១៤- ២០១៨) ក៏ដូចជាកិច្ចដំណើរការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ។

---

[12] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១០។

[13] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១០។

[14] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១០។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រំពឹងលទ្ធភាពកែលម្អចំពោះចំណេះដឹងផ្អែកលើវិទ្យាសាស្ត្រ ការអភិវឌ្ឍសមត្ថភាព ការផ្ទេរបច្ចេកវិទ្យា និង ហិរញ្ញប្បទានអាកាសធាតុ ពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានជួយសម្រួលដោយកិច្ចព្រមព្រៀង ក្រុងប៉ារីសប្រកបដោយមហិច្ឆតាមួយ។

ប្រទេសកម្ពុជាបច្ចុប្បន្នធ្វើការងារលើ INDC របស់ខ្លួន និង គ្រោងប្រគល់ងអោយបានមុនសន្និសីទក្រុងប៉ារីស។ ទោះបីជាការបញ្ចេញឧស្ម័ន $CO_2$ របស់ប្រទេសមានលក្ខណៈទាបខ្លាំងក៏ដោយ ($CO_2$ចំនួន ៤ លានតោនក្នុងមួយឆ្នាំ ពោលគឺ ០.២៥ តោនក្នុងប្រជាជនម្នាក់) ក៏ប្រទេសបានតាំងចិត្តងាកទៅកាន់មាគ៌ាកាបូនទាបមួយដែរ ប្រសិនបើភាគទានរបស់ប្រទេសត្រូវបានចាត់ទុកថាជាភាគទានដោយស្ម័គ្រចិត្ត និង ថាបណ្តាប្រទេសដែលអាចធ្វើដូច្នេះបានគាំទ្រកម្ពុជា។

ជាទូទៅ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសង្គមស៊ីវិលគាំទ្រជំហររបស់ប្រទេស LDC ជាពិសេសគោលដៅពាក់ព័ន្ធរយៈពេលវែង ១,៥°C។ ហេតុដូច្នេះ ប្រទេសបញ្ចេញឧស្ម័នធំៗទាំងអស់ ត្រូវបានរំពឹងថានឹងបង្ហាញ INDCs ដែលមានសង្គតិភាពជាមួយគោលដៅរយៈពេលវែង ប្រកបដោយមហិច្ឆតានេះ។ ចំពោះហិរញ្ញប្បទានអាកាសធាតុ ប្រទេសកម្ពុជាអំពាវនាវឲ្យមានការបង្កើនល្បឿនលទ្ធភាពទទួលហិរញ្ញប្បទាននេះ និង កូតាជាក់លាក់សម្រាប់ប្រទេស LDC។ ភាគីដែលមិនស្ថិតក្នុងឧបសម្ព័ន្ធ ១ ក៏ត្រូវបានរំពឹងផងដែរថានឹងផ្តល់ជាជំហានៗ នូវហិរញ្ញប្បទានអាកាសធាតុ និង ការគាំទ្រ។ ការបង្កើនការកសាងសមត្ថភាព គឺជាភារកិច្ចគន្លឹះមួយទៀត។ ចំពោះការបាត់បង់ និង ការខូចខាត ទស្សនៈរួមគឺថាការបាត់បង់ផ្នែកសេដ្ឋកិច្ច គប្បីត្រូវកត់ត្រានិងរាយការណ៍ជាប្រព័ន្ធ តាមទម្រង់តែមួយគត់។

ជារួម រាជរដ្ឋាភិបាលកម្ពុជា និង សង្គមស៊ីវិល ចាត់ទុកក្រុមប្រទេស LDC ថាជាមូលដ្ឋាននយោបាយរបស់ខ្លួននៅក្នុងការជជែកអំពីអាកាសធាតុ។ ចំណុចនេះ ក៏ដូចគ្នាអញ្ចឹងដែរ ក្នុងកម្រិតទាបជាងសម្រាប់ក្រុមប្រទេសកំពុងអភិវឌ្ឍន៍ ៧៧ (G77) + ចិន។ ឧទាហរណ៍ AOSIS និង សហភាពអឺរ៉ុប ត្រូវបានចាត់ទុកថាជាសក្តានុពលសម្ព័ន្ធមិត្ត។

## ជំហរគន្លឹះនៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច

<u>គោលដៅរយៈពេលវែង /គោលដៅទូទៅ:</u> ក្រុមប្រទេស LDC អំពាវនាវឲ្យកំណត់គោលដៅកម្រិតសីតុណ្ហភាព ១,៥°C ដែលត្រូវដំណើរការដោយការបញ្ចប់ជាបណ្តើរៗនូវការបញ្ចេញឧស្ម័នកាបូនអនុលោមតាមវិទ្យាសាស្ត្រ។[15] របាយការណ៍វាយតម្លៃទី ៥ របស់ IPCC លើកឡើងថាការបញ្ចេញ

[15] បញ្ហាបច្ចេកទេសនិងនយោបាយសំខាន់ៗសម្រាប់ប្រទេសអភិវឌ្ឍទាបបំផុតក្រោម, LDC Paper Series, Pa Ousman Jarju & Tim Gore, ឆ្នាំ ២០១៣, ទំព័រ ១។

ឧស្ម័នសុទ្ធកម្រិតសូន្យ ត្រូវសម្រេចឲ្យបានមុនឆ្នាំ ២០៥០ ប្រសិនបើកំណើនសីតុណ្ហភាពមធ្យមពិភពលោកគប្បីត្រូវរក្សាឲ្យស្ថិតនៅក្រោម ១,៥°C ជាមួយប្រូបាប៊ីលីតេយ៉ាងហោចណាស់ ៥០%។

គោលដៅបន្ស៊ាំ: ក្រុមប្រទេស LDC អំពាវនាវឲ្យមានគោលដៅបន្ស៊ាំមួយដើម្បីពូនជ្រំភាពធន់នឹងអាកាសធាតុ និង ដើម្បីធ្វើឲ្យមានតុល្យភាព រវាងការកាត់បន្ថយហេតុនិងការបន្ស៊ាំ នៅក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស។ គោលដៅបន្ស៊ាំ ត្រូវផ្សារភ្ជាប់ជាមួយមហិច្ឆតាកាត់បន្ថយហេតុ និង ការផ្តល់ការគាំទ្រ រួមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុ ពោលគឺ "ធនធានហិរញ្ញវត្ថុបន្ថែមថ្មី គ្រប់គ្រាន់និងអាចព្យាករណ៍បានសម្រាប់ការបន្ស៊ាំ"។[16]

ទម្រង់ច្បាប់: ក្រុមប្រទេស LDC អំពាវនាវឲ្យមានពិធីសារមួយ ដែលត្រូវអនុវត្ត ចំពោះគ្រប់ភាគីទាំងអស់ ប៉ុន្តែ មានការសន្យាខុសៗគ្នាដែលឆ្លុះបញ្ចាំងយ៉ាងគ្រប់គ្រាន់នូវកាលៈទេសៈពិសេសរបស់ LDCs និង SIDS។

ការកាត់បន្ថយបុព្វហេតុ: ក្រុមប្រទេស LDC ស្នើឲ្យបណ្តាប្រទេសបញ្ចេញឧស្ម័នធំៗទាំងអស់បង្កើនកម្រិតមហិច្ឆតាឲ្យបានស្របតាមគោលដៅកម្រិតសីតុណ្ហភាព ១,៥°C ជាមួយកម្រិត វិសាលភាព និង ប្រភេទនៃការសន្យាមានលក្ខណៈខុសគ្នា យោងតាមក្របខ័ណ្ឌយោងសមធម៌ (Equity Reference Framework)។[17]

ការបន្ស៊ាំ និង ការបាត់បង់និងការខូចខាត: ក្រុមប្រទេស LDC អំពាវនាវឲ្យពង្រឹងគណៈកម្មាធិការបន្ស៊ាំ នឹង អាកាសធាតុ ផែនការជាតិបន្ស៊ាំ នឹង ការប្រែប្រួលអាកាសធាតុ (NAPs) ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការបន្ស៊ាំ (រួមទាំងវង្វាស់) និង ក្របខ័ណ្ឌស្ថាប័នកាន់តែរឹងមាំមួយ ដើម្បីដោះស្រាយការបាត់បង់និងការខូចខាត ដោយធានាឲ្យបាននូវការផ្តល់សំណងចំពោះការបាត់បង់ហួសពីលទ្ធភាពបន្ស៊ាំ ជាមួយយន្តការផ្តល់មូលនិធិខ្លួនឯងមួយ។[18]

ហិរញ្ញវត្ថុ: យ៉ាងហោចណាស់ ១០០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំមុនឆ្នាំ ២០២០ ដែលជាកូតាបន្ថែមថ្មីបម្រុងទុកសម្រាប់កូតាការបន្ស៊ាំ និង កូតាប្រទេសអភិវឌ្ឍន៍តិចតួច (LCD) ជាមួយលទ្ធភាពទទួលបាន ក្នុងលក្ខខណ្ឌលឿន និងអនុគ្រោះ និងវិភាគទានរបស់បណ្តាប្រទេសអ្នកមានទាំងអស់។

---

[16] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១០។

[17] ការប្តេជ្ញាកាត់បន្ថយក្នុងលក្ខណៈខុសៗគ្នាស្តីពីកិច្ចព្រមព្រៀងអាកាសធាតុថ្មីមួយ, LDC Paper Series, Niklas Höhne et al, ឆ្នាំ ២០១៤។

[18] អភិវឌ្ឍក្របខ័ណ្ឌស្ថាប័នមួយដើម្បីដោះស្រាយការបាត់បង់និងការខូចខាត, LDC Paper Series, Erin Roberts et al, ឆ្នាំ ២០១៤។

តម្លាភាពនៃសកម្មភាពនិងការគាំទ្រ: វិធាននិងគោលការណ៍តម្លាភាពនិងគណនេយ្យភាព ដែលត្រូវពង្រឹងដើម្បីជៀសវាង 'ប្រទេសឱកាសនិយម' និង ដើម្បីបង្កើនមហិច្ឆតា និង យុត្តិធម៌។[19]

ក្របខ័ណ្ឌពេលវេលា និង បញ្ញានីតិវិធី: ការពិនិត្យវាយតម្លៃទៀងទាត់ក្នុងវដ្ត ៥ ឆ្នាំ។

ការជួយសម្រួលការអនុវត្ត និង អនុលោមភាព: ក្រុមប្រទេស LDC អំពាវនាវឲ្យមានយន្តការមួយដើម្បីពិនិត្យមើលឡើងវិញ និងវាយតម្លៃផ្នែកបច្ចេកទេសលើការអនុវត្តការសន្យា ដែលនាំទៅដល់ការបង្កើនការសន្យាជាហូរហែរ ដោយមិនឲ្យមានការធាក់ថយក្រោយវិញ។[20]

មហិច្ឆតាមុនឆ្នាំ ២០២០: ក្រុមប្រទេស LDC ជំរុញឲ្យក្រុមប្រទេសអភិវឌ្ឍបង្កើនមហិច្ឆតាមុនឆ្នាំ ២០២០ ដើម្បីតាមដានមើលវឌ្ឍនភាព និងដើម្បីប្រើនិងគាំទ្រជម្រើសរយៈពេលខ្លីនានា ដូចជាការដាក់ពង្រាយថាមពលកកើតឡើងវិញ និងការបញ្ចប់ជាបណ្តើរៗ នូវការឧបត្ថម្ភធនដល់ឥន្ធនៈហ្វូស៊ីល។[21]

## ជម្រើសគោលនយោបាយដើម្បីសម្រេចបានលទ្ធផលប្រសើរបំផុតដែលអាចមាន

### គោលដៅរយៈពេលវែង

កិច្ចព្រមព្រៀងស្តីពីគោលដៅរយៈពេលវែងកំណត់មួយ សំខាន់ គឺដើម្បីណែនាំភាគីក្នុងការជំរុញការសន្យារបស់ខ្លួន និងដើម្បីវាស់វឌ្ឍនភាព។ ខណៈពេលដែលគោលដៅសីតុណ្ហភាព ២°C ត្រូវបានទទួលយកយ៉ាងទូលាយរួចហើយក្តី ក៏គោលដៅសីតុណ្ហភាពពោរពេញដោយមហិច្ឆតា ១,៥°C ដែលត្រូវបានស្នើឡើងដោយកម្ពុជា និងក្រុមប្រទេស LDC មិនត្រូវបានទទួលយកយ៉ាងទូលាយទេ[22]: គោលដៅនេះអាចពឹងផ្អែកលើការគាំទ្ររបស់ប្រទេស LDC, AOSIS និងក្រុមប្រទេសអាហ្វ្រិក ប៉ុន្តែ វាមិនទំនងជាត្រូវបានទទួលយកដោយប្រទេសដទៃទៀតឡើយ ជាពិសេស បណ្តាប្រទេស

---

[19] បញ្ហាបច្ចេកទេសនិងនយោបាយសំខាន់ៗសម្រាប់ប្រទេសអភិវឌ្ឍទាបបំផុតក្រោម, LDC Paper Series, Pa Ousman Jarju & Tim Gore, ឆ្នាំ ២០១៣, ទំព័រ ១។

[20] ការប្តេជ្ញាកាត់បន្ថយក្នុងលក្ខណៈខុសៗគ្នាស្តីពីកិច្ចព្រមព្រៀងអាកាសធាតុថ្មីមួយ, LDC Paper Series, Niklas Höhne et al, ឆ្នាំ ២០១៤។

[21] ឯកសារដដែល

[22] យោងតាមការគណនាវិទ្យាសាស្ត្រ ថវិកាកាបូននៅសល់ ដែលអាចត្រូវបានបញ្ចេញរហូតដល់ពេលដែលសីតណ្ហភាពមធ្យមកើនឡើង ១.៥°C គឺមានតែ ២៤៣ ពាន់លានតោនប៉ុណ្ណោះ។ ក្នុងកម្រិតបញ្ចេញឧស្ម័នប្រចាំឆ្នាំបច្ចុប្បន្ន ៤០.៣ ពាន់លានតោន ថវិកានៅសល់នឹងត្រូវបានចំណាយក្នុងរយៈពេលតែប្រាំមួយឆ្នាំប៉ុណ្ណោះ។ ចំណុចនេះ បង្ហាញថាតើគោលដៅសីតណ្ហភាព ១.៥°C មានមហិច្ឆតាកម្រិតណា។ ដើម្បីព័ត៌មានបន្ថែម សូមមើល http://www.carbonbrief.org/blog/2014/11/six-years-worth-of-current-emissions-would-blow-the-carbon-budget-for-1-point-5-degrees/

បញ្ចេញឧស្ម័នធំៗ។ ចំណុចរួម អាចជាការកំណត់តែកម្រិតវង្ស់សម្រាប់គោលដៅសីតុណ្ហភាព ពោលគឺ ១.៥/២°C ដូចដែលត្រូវបានធ្វើកន្លងមកនៅក្នុងសេចក្តីសម្រេច CoP ជាច្រើន។

គោលដៅសីតុណ្ហភាពមួយដែលអាចដំណើរការបានខាងនយោបាយ គឺគប្បីត្រូវអមដោយគោលដៅកាត់បន្ថយកាបូនមួយ ជាមួយក្របខ័ណ្ឌលពេលវេលាកំណត់មួយ។ បើពុំដូច្នោះទេ គេនឹងមានការលំបាកខ្លាំងក្នុងការប្រែក្លាយការកាត់បន្ថយទៅជាគោលដៅជាក់ស្តែង។ គោលដៅកាត់បន្ថយកាបូនជាក់ស្តែងមួយ ដែលអំពាវនាវឲ្យសម្រេចបាន "ការបញ្ចេញឧស្ម័នសុទ្ធកម្រិតសូន្យ" មុនកាលបរិច្ឆេទជាក់លាក់មួយ គប្បីក្លាយជាការទាមទារគន្លឹះមួយរបស់កម្ពុជា ដោយសារប្រទេសគិតគូរពីគោលដៅសីតុណ្ហភាពយ៉ាងម៉ឺងម៉ាត់។ គេអាចអះអាងយ៉ាងត្រឹមត្រូវថាប្រទេសកម្ពុជាមានកាតព្វកិច្ចកាត់បន្ថយហានិភ័យហួសហេតុ នៃការឡើងសីតណ្ហភាពគ្មានការគ្រប់គ្រង ដែលជាពិសេស អាងទន្លេមេគង្គកំពុងប្រឈមមុខ។

ប៉ុន្តែ ភាគីទំនងជានឹងមិនឯកភាពតាមការយល់ព្រមលើគោលដៅកាត់បន្ថយកាបូនមួយ ជាមួយក្របខ័ណ្ឌពេលវេលាផ្អែកលើវិទ្យាសាស្ត្រ ដែលនឹង មានសង្គតិភាពជាមួយ ១.៥/២°C ពោលគឺឆ្នាំ ២០៥០/២០៧០៖ ទាំងក្រុមប្រទេសអារ៉ាប់ ក្រុមឆ័ត្រ (ដែលដឹកនាំដោយសហរដ្ឋអាមេរិក) ប្រទេសប្រេស៊ីល ចិន ឥណ្ឌា និង អាហ្វ្រិកខាងត្បូង (BASIC) និងក្រុមប្រទេសមានគំនិតដូចគ្នា (LMDC) ប្រហែលជាប្រឆាំងនឹងជំហានមួយបែបនេះ ខណៈពេលដែល AOSIS, AILAC ក្រុមប្រទេសអាហ្វ្រិក និង សហភាពអឺរ៉ុបប្រហែលជានឹងផ្តល់ការគាំទ្រ។

ចំណុចកណ្តាលមួយ អាចគឺជាការឯកភាពលើការសម្រេចការបញ្ចេញឧស្ម័នកាបូនសុទ្ធកម្រិតសូន្យ ដោយមិននិយាយអំពីពេលវេលា ឬ បើអាចធ្វើបាន រួមមានការនិយាយយោងដល់ IPCC នៅពេលនិយាយអំពីនិយមន័យនៃក្របខ័ណ្ឌពេលវេលា។ សេចក្តីសម្រេច COP មួយ អាចត្រូវបានបន្ថែម ដោយអំពាវនាវឲ្យមានការពិភាក្សាអំពីក្របខ័ណ្ឌ ពេលវេលានៅក្នុងការពិនិត្យវាយតម្លៃទីមួយ ឧទាហរណ៍ ឆ្នាំ ២០២៥។ ចំណុចល្អនៃជំហានមួយបែបនេះ គឺការកំណត់យ៉ាងច្បាស់នូវ "ការបញ្ចេញឧស្ម័នកាបូនសុទ្ធកម្រិតសូន្យ" ថាជានិយមន័យត្រឹមត្រូវ និង សមស្របទៅតាមមហិច្ឆតាកាត់បន្ថយ (ត្រឹមត្រូវជាង "ការកាត់បន្ថយកាបូន") នៅក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស។ ដូច្នេះសញ្ញា ដ៏ច្បាស់មួយនឹងត្រូវបានផ្ញើជូនគ្រប់ភាគីពាក់ព័ន្ធទាំងអស់ អំពីទិសដៅទូទៅ ប៉ុន្តែចំណុចជាក់លាក់ (ពោលគឺ ក្របខ័ណ្ឌពេលវេលា) នឹងត្រូវកំណត់នៅពេលក្រោយ។ ការប្រើពាក្យនេះ គប្បីត្រូវបានពិភាក្សានៅកម្ពុជា ក្នុងក្រុមប្រទេស LDC និង ជាមួយសម្ព័ន្ធមិត្តជាសក្តានុពលនៅក្នុងជំហានមួយទៀត។

បណ្តាប្រទេសបញ្ចេញឧស្ម័នធំៗ ទំនងជានឹងមិនបង្កើនការសន្យាអាកាសធាតុ របស់ពួកគេដល់កម្រិតចាំបាច់មុនសន្និសីទក្រុងប៉ារីសទេ។ ដូច្នេះ កិច្ចព្រមព្រៀងស្តីពីគោលដៅរយៈពេលវែងដោយគ្មានយន្តការអនុវត្តមួយទំនងជាមិនសម្រេចបានទេ។ វាគឺជាគំនិតល្អដែលគួរអំពាវនាវឲ្យមានយន្តការពិនិត្យវាយតម្លៃទៀងទាត់មួយ ជាឧបករណ៍គន្លឹះមួយនៃកិច្ចព្រមព្រៀងស្នូល ដើម្បីសម្រេចបានគោលដៅរយៈពេលវែង។ ទោះបីជាយន្តការពិនិត្យវាយតម្លៃបែបនេះមិនទំនងជានឹងត្រូវបានបំពាក់ដោយយន្តការដាក់ទណ្ឌកម្ម ឬ អាចបង្ខំភាគីពីលើចុះក្រោមឲ្យបង្កើនការសន្យារបស់ខ្លួនជាហូរហែរក្តី ក៏ យន្តការនេះនៅតែអាចធ្វើឲ្យមានភាពខុសគ្នាដ៏ធំមួយដែរធៀបទៅនឹងចំណាត់ការ "សន្យាដោយគ្មានការពិនិត្យវាយតម្លៃ"៖ លេខាធិការដ្ឋាន UNFCCC អាចត្រូវបានប្រគល់ភារកិច្ចឲ្យធ្វើការពិនិត្យវាយតម្លៃផ្អែកលើវិទ្យាសាស្ត្រ ដោយប្រៀបធៀបក្នុងវដ្ត ៥ ឆ្នាំ នូវការកាត់បន្ថយការបញ្ចេញឧស្ម័នសរុបដែលសម្រេចបានជាមួយគន្លងផ្លូវបញ្ចេញឧស្ម័ន ១.៥/២°C ដូចដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍វាយតម្លៃចុងក្រោយបំផុតរបស់ IPCC។ ផ្អែកលើលទ្ធផលនៃការពិនិត្យវាយតម្លៃ ភាគីទាំងអស់នឹងត្រូវបានស្នើឲ្យបង្កើនជាបណ្តើរៗនូវ INDC របស់ខ្លួន អនុលោមតាមគោលការណ៍ក្រុងរីយ៉ូ និង កាលៈទេសៈជាតិជាក់ស្តែង និង រួមគ្នាសំដៅភ្ជិតគម្លាតបញ្ចេញឧស្ម័នឲ្យបានយ៉ាងឆាប់តាមដែលអាចធ្វើបាន ប៉ុន្តែ មិនឲ្យហួសពីឆ្នាំ ២០៧០ អនុលោមតាម IPCC។ ការធាក់ថយក្រោយនឹងត្រូវទប់ស្កាត់។

យន្តការបែបនេះមួយ មិនផ្តល់ការធានាឲ្យស្ថិតនៅក្រោម ១.៥°C/២°C ទេ ប៉ុន្តែ គឺជាបុព្វលក្ខខណ្ឌមួយសម្រាប់ធ្វើដូចនេះ។ យន្តការនេះ គឺអនុលោមតាមជំហររបស់ប្រទេស LDC និង មានការគាំទ្រជាចម្បងរបស់ AOSIS, AILAC ក្រុមប្រទេសអាហ្វ្រិក និងសហភាពអឺរ៉ុប។ សមាជិកនៃក្រុមសុចរិតភាពបរិស្ថាន (Environmental Integrity Group) និង សហរដ្ឋអាមេរិក ក៏ហាក់ដូចជាគាំទ្រការពិនិត្យវាយតម្លៃផងដែរ ហើយវានឹងពិបាកសម្រាប់ប្រទេសដទៃក្នុងការបដិសេធជាចុងក្រោយ ឬ រំលាយចោលទាំងស្រុងនូវយន្តការបែបនេះ។ ដើម្បីធានាសុចរិតភាពនៃយន្តការនេះ និង ដើម្បីជៀសវាងប្រទេសឱកាសនិយម វាគឺជាប្រការសំខាន់បំផុតដែលត្រូវធានាឲ្យបានថាការពិនិត្យវាយតម្លៃត្រូវអនុវត្តចំពោះគ្រប់ប្រទេសទាំងអស់។ ដោយគិតគូរដល់កាលៈទេសៈពិសេសនៃប្រទេស ករណីលើកលែងខ្លះអាចត្រូវបានផ្តល់ជូនបណ្តាប្រទេសមានប្រាក់ចំណូលទាប សម្រាប់ពេលបច្ចុប្បន្ន។

### តម្លាភាព និង គណនេយ្យភាពនៃសកម្មភាពនិងការគាំទ្រ

ដើម្បីធានាឲ្យមានតម្លាភាព និង គណនេយ្យភាពនៃសកម្មភាពនិងការគាំទ្រ រួមទាំងយុត្តិធម៌ និង សមធម៌ កិច្ចព្រមព្រៀងស្នូលគប្បីរួមមានក្របខ័ណ្ឌតម្លាភាពផ្លូវការមួយ៖ ក្របខ័ណ្ឌនេះ យ៉ាង

ហោចណាស់ ត្រូវកំណត់គោលការណ៍រួម ដែលត្រូវអនុវត្តចំពោះភាគីទាំងអស់ របៀបរាយការណ៍ និង ផ្ទៀងផ្ទាត់ការអនុវត្ត យ៉ាងទៀងទាត់ នូវសកម្មភាពកាត់បន្ថយដែលបានសន្យានៅថ្នាក់ជាតិ និង ការផ្តល់ការគាំទ្រ ដែលនាំទៅដល់ការរៀបចំរបាយការណ៍ប្រចាំប្រទេសរាល់ពីរឆ្នាំម្តង ដោយអនុវត្តតាមរចនាសម្ព័ន្ធនិងលក្ខណៈវិនិច្ឆ័យផ្លូវការដូចគ្នាមួយ ដែលត្រូវបកស្រាយពន្យល់ដោយស្ថាប័នជំនាញជាតិដែលត្រូវបានតែងតាំង និងត្រូវបានផ្ទៀងផ្ទាត់ដោយជំនាញការបច្ចេកទេសឯករាជ្យ ដែលត្រូវបានប្រគល់សិទ្ធិដោយលេខាធិការដ្ឋាន UNFCCC។ របាយការណ៍ប្រចាំប្រទេស គប្បីត្រូវបានពិចារណាយ៉ាងត្រឹមត្រូវនៅក្នុងសម័យប្រជុំរាយការណ៍នៃស្ថាប័នឯកទេសមួយក្រោមកិច្ចព្រមព្រៀងថ្មីនេះ ជាផ្នែកមួយនៃការពិនិត្យវាយតម្លៃថ្មីដែលបានលើកឡើងខាងលើ។ តម្លាភាពនិងគណនេយ្យភាព គឺជាបុព្វលក្ខខណ្ឌសម្រាប់ការពិនិត្យវាយតម្លៃទៀងទាត់ផ្អែកលើវិទ្យាសាស្ត្រ ដើម្បីជៀសវាងការគ្មានអនុលោមភាព ដើម្បីដោះស្រាយគម្លាតនៅសល់ និង ជាចុងក្រោយ ដើម្បីកៀរគរមហិច្ឆតាអតិបរមាដែលចាំបាច់ដើម្បីរក្សាសីតុណ្ហភាពនៅក្រោយ ១.៥/២°C។ បើគ្មានតម្លាភាព ការពិនិត្យវាយតម្លៃ និង គោលដៅរយៈពេលវែង ទំនងជានឹងគ្មានប្រសិទ្ធភាពទេ។

ការមិនអាចបំពេញតាមស្តង់ដារកំណត់ និងបន្ទុកធ្ងន់ពីការបង្កើតស្ថាប័នចាំបាច់ គឺជាកង្វល់ដ៏ធំមួយរបស់ប្រទេសកម្ពុជា ក៏ដូចជាប្រទេស LDC និង SIDS ដទៃទៀតដែរ។ ប្រទេសកម្ពុជាគប្បីអះអាង សូម្បីឈានដល់ខ្សែបន្ទាត់ក្រហម ថាសេចក្តីត្រូវការនិងស្ថានភាពពិសេសរបស់ប្រទេស LDC, SIDS និង ប្រទេសមានប្រាក់ចំណូលទាបដទៃទៀត គប្បីត្រូវបានពិចារណាយ៉ាងពេញលេញ ដោយយល់ព្រម ទទួលយករយៈពេល អន្តរកាលវែងជាងមួយ រហូតដល់ពេលត្រូវប្រគល់របាយការណ៍ប្រចាំប្រទេសទីមួយ និង ដោយធានាឲ្យបាននូវការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសចាំបាច់សម្រាប់កសាងសមត្ថភាពស្ថាប័ន និង លក្ខខណ្ឌរាយការណ៍។

វាគឺជាប្រការច្បាស់ណាស់ដែលបណ្តាប្រទេសបញ្ចេញឧស្ម័នធំៗជាច្រើន ជាពិសេស ប្រទេសខ្លះបើសិនជាមិនមែនប្រទេសស្ទើរតែទាំងអស់ នៃបណ្តាប្រទេសមានសេដ្ឋកិច្ចងើបឡើងថ្មី ក៏ដូចជាបណ្តារដ្ឋនាំចេញប្រេងកាត និង LMDCs ជាដើម នឹងព្យាយាមគេចវេសវិធានតម្លាភាពដូចគ្នាដែលត្រូវអនុវត្តលើពួកគេ ដូចគ្នាលើបណ្តាប្រទេសអភិវឌ្ឍដែរ។ ពួកគេប្រកែកជាមួយការបកស្រាយអនុសញ្ញាក្នុងលក្ខណៈអភិរក្សមួយ បដិសេធខ្លះៗនូវការអះអាងដែលថាការទទួលខុសត្រូវ និងសមត្ថភាពវិវត្តជាបណ្តើរៗ និង ជំរុញការពង្រីកការបែងចែករវាងបណ្តាប្រទេសស្ថិតក្នុងឧបសម្ព័ន្ធ ១ និង បណ្តាប្រទេសមិនស្ថិតក្នុងឧបសម្ព័ន្ធ ១ នៅក្នុងកិច្ចព្រមព្រៀងក្រោយឆ្នាំ ២០២០។ ចំពោះមុខប្រការដែលថាការបញ្ចេញឧស្ម័ន សរុបរបស់បណ្តាប្រទេសមានសេដ្ឋកិច្ចងើបឡើងថ្មីធំបំផុតទាំងប្រាំពីរ (E7) សម្រាប់ឆ្នាំ ១៩៩០ – ២០៣០ ត្រូវបានរំពឹងថានឹងកើនឡើងស្មើជិតទ្វេដងនៃការ

បញ្ចេញឧស្ម័នរបស់បណ្តាប្រទេសឧស្សាហកម្មធំបំផុតទាំង ៧ (G7) គេមើលឃើញច្បាស់ថាគោលដៅ ១.៥/២°C អាចសម្រេចបានតែជាមួយវិធានត្រូវអនុវត្តចំពោះប្រទេសទាំងអស់។ តួនាទីជាសក្តានុពលរបស់ប្រទេស LDC និង AOSIS ក្នុងការសម្រេចបានគោលដៅនេះ មានលក្ខណៈសំខាន់ជាយុទ្ធសាស្ត្រ: បណ្តាប្រទេសឧស្សាហកម្មដែលមានមហិច្ឆតាអាកាសធាតុខ្លាំង ពោលគឺសហភាពអឺរ៉ុប ទំនងជានឹងមិនអាចសម្រេចបានវិធានតម្លាភាពរឹងមាំ ដោយគ្មានការគាំទ្រពីបណ្តាប្រទេសងាយរងគ្រោះពីអាកាសធាតុទេ។ ទន្ទឹមនឹងនេះ ប្រទេសកំពុងអភិវឌ្ឍមានគំនិតដូចគ្នា (LMDC) និងបណ្តាប្រទេសមានសេដ្ឋកិច្ចងើបឡើងថ្មី នឹងមានការលំបាកក្នុងការជំរុញវិធានតម្លាភាពទន់ខ្សោយប្រឆាំងនឹងបំណងប្រាថ្នារបស់បណ្តាប្រទេសងាយរងគ្រោះពីអាកាសធាតុ។

ចំណុចបច្ចេកទេសទាំងអស់មិនទំនងជាអាចបំភ្លឺបានជាស្រេចទេនៅប៉ារីស។ អាស្រ័យហេតុនេះ តាមសេចក្តីសម្រេច COP ដោយឡែកមួយ កម្មវិធីការងារគប្បីត្រូវបង្កើតដើម្បីអភិវឌ្ឍចំណុចពិស្តារនៃវិធីសាស្ត្រអនាគតដើម្បីវាស់ រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) អនុលោមភាពជាមួយការសន្យា។

ចំពោះការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និង មធ្យោបាយអនុវត្តផ្សេងៗទៀត ដូចដែលត្រូវបានរំពឹងពីបណ្តាប្រទេសអភិវឌ្ឍ និង ប្រទេសដទៃទៀតដែលអាចធ្វើដូច្នេះបាន តម្លាភាពនិងគណនេយ្យភាពគប្បីត្រូវធានាឲ្យបាន ដោយការរាយការណ៍ទៀងទាត់ តាមស្តង់ដារដូចគ្នា អំពីការគាំទ្រដែលបានផ្តល់ ទោះបីគឺជាផ្នែកមួយនៃរបាយការណ៍ស្តីពីសកម្មភាពកាត់បន្ថយ ឬ គឺជាដាច់ដោយឡែក ឬបន្ថែមលើរបាយការណ៍ទាំងនោះក៏ដោយ។ ក្របខ័ណ្ឌតម្លាភាពនិងគណនេយ្យភាពមួយ ត្រូវបានចាត់ទុកថាសំខាន់ក្រៃលែង ទាក់ទិននឹងការផ្តល់ការគាំទ្រនៅកម្រិតជាតិ រួមមានទំនាក់ទំនងរវាងរដ្ឋាភិបាល តួអង្គឯកជន និង សង្គមស៊ីវិល។

## ការបន្សាំ និងការបាត់បង់ និងការខូចខាត-ពង្រឹងធាពធន់នឹងអាកាសធាតុ

ប្រទេសកម្ពុជា និងក្រុមប្រទេស LDC មានការរំពឹងទុកខ្ពស់ថានឹងពង្រឹងយ៉ាងខ្លាំងនូវការបន្សាំ និងការបាត់បង់ និង ការខូចខាត ជាផ្នែកដ៏សំខាន់នៃកញ្ចប់ក្រុងប៉ារីស ដែលជំរុញការអភិវឌ្ឍបញ្ចេញកាបូនទាបនិងធន់នឹងអាកាសធាតុ និងដែលកាត់បន្ថយហានិភ័យអាកាសធាតុដល់កម្រិតអប្បបរមាតាមដែលអាចធ្វើទៅបាន។

សូមផ្តល់អនុសាសន៍ សូមឲ្យរក្សាការទាមទារដ៏ខ្លាំងក្លាឲ្យមានគោលដៅបន្សាំ និង ភាពធន់នឹងអាកាសធាតុរយៈពេលវែងជាផ្នែកដ៏សំខាន់មួយនៃកិច្ចព្រមព្រៀងសកល។ សូមស្នើឲ្យទាមទារឲ្យមានគោលដៅបន្សាំបែបគុណភាពជាជាងបែបបរិមាណ ដែលកំណត់ឲ្យភាគីទាំងអស់ អនុលោមតាមគោលការណ៍និងបទប្បញ្ញត្តិនៃអនុសញ្ញា ក្របខ័ណ្ឌសេនដាយដើម្បីសកម្មភាព (Sendai

Framework for Action) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង SDGs បង្កើនភាពធន់ នឹងអាកាសធាតុដោយវាយតម្លៃ និងកាត់បន្ថយជាប្រព័ន្ធនូវហានិភ័យអាកាសធាតុ ដោយបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង ដោយកាត់បន្ថយភាពងាយរងគ្រោះ។ ម្យ៉ាងទៀត គោលដៅរយៈពេលវែងគប្បីកំណត់ឲ្យបណ្តាប្រទេសអភិវឌ្ឍ និង ភាគីផ្សេងៗទៀតដែលមានលទ្ធភាពអាចធ្វើបាន ផ្តល់ការជួយគាំទ្រខាងហិរញ្ញវត្ថុ បច្ចេកវិទ្យា និង កសាងសមត្ថភាព ជូនដល់ភាគីទាំងឡាយដែល ត្រូវទទួលបន្ទុកលើសលុបដោយការគ្រប់គ្រង ផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ដើម្បីជំរុញគោលដៅបន្សាំ និង ភាពធន់នឹងអាកាសធាតុរយៈពេលវែងមួយ បែបនេះ ការអនុវត្តគោលដៅនេះគប្បីត្រូវបានគាំទ្រដោយការឧបត្ថម្ភរបស់ប្រទេសទាំងអស់ដើម្បីអភិវឌ្ឍ អនុវត្ត និង គាំទ្រផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រួមទាំងការវាយតម្លៃជាប្រព័ន្ធនូវហានិភ័យអាកាសធាតុ និង នៅទីណាសមស្រប កសាងលើវឌ្ឍនភាពអន្តរកាលបច្ចុប្បន្នពី NAPA ទៅកាន់ NAPs[23]។ លទ្ធផលនៃសកម្មភាពបន្សាំជាតិ គប្បីត្រូវបានវាយតម្លៃយ៉ាងទៀតទាត់ និង ចងក្រងជាឯកសារនៅក្នុងរបាយការណ៍បន្សាំជាតិ ។ ចំណុចនេះនឹងជួយប្រទេសកម្ពុជា ក្នុងការរៀបចំរចនាសម្ព័ន្ធតាមដាននិងវាយតម្លៃ ដូចដែលត្រូវបានពិព័ណ៌នានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៣-២០២២[24]។ កិច្ចប្រឹងប្រែងបន្សាំគប្បីត្រូវបានគាំទ្រដោយក្របខ័ណ្ឌគោលនយោបាយនិងស្ថាប័នប្រកបដោយប្រសិទ្ធភាព មានជាអាទិ៍ គណៈកម្មាធិការបន្សាំនឹងអាកាសធាតុ។ គោលដៅបន្សាំបែបគុណភាពនេះ អាចសម្រេចបាន ប៉ុន្តែ គេមិនទំនងជាសម្រេចបានគោលដៅបន្សាំបែបបរិមាណទេ ពោលគឺ រួមមានការផ្តល់ការគាំទ្របែបបរិមាណដល់ការបន្សាំ ដែលត្រូវបានយល់ព្រមធៀបនឹងឆន្ទៈប្រកាសរបស់ប្រទេសអភិវឌ្ឍទាំងអស់ ពោលគឺម្ចាស់ជំនួយសំខាន់ៗ។ ប៉ុន្តែ ប្រការនេះមិនមែនសុទ្ធតែមានន័យថាត្រូវបោះបង់ការស្នើសុំហិរញ្ញប្បទានទុកបម្រុងសម្រាប់ការបន្សាំទេ៖ ដូចវិធាននៃមូលនិធិអាកាសធាតុបៃតងបង្ហាញអញ្ចឹង គេអាចឯកភាពលើកូតាហិរញ្ញវត្ថុអប្បបរមា សម្រាប់ប្រទេស LDC ក៏ដូចជាលើកូតាបន្សាំមួយ។

ក្រៅពីការបន្សាំ ការបាត់បង់និងការខូចខាតគឺជាបញ្ហាមួយនៃបញ្ហារសើបដ៏ចម្រូងចម្រាស់បំផុតៈ ក្រុមប្រទេស LDC ទាមទារសំណង យ៉ាងច្បាស់លាស់ និង យ៉ាងខ្លាំង ខណៈពេលដែលការទាមទារនេះ និង សូម្បីតែពាក្យនេះ ក៏ប្រាកដគឺជាខ្សែបន្ទាត់ក្រហមមួយសម្រាប់បណ្តាប្រទេសឧស្សាហកម្ម

[23] https://ldcclimate.files.wordpress.com/204/03/updated-napas-and-naps1.pdf ទំព័រ ១, ២, និង ៣។

[24] រាជរដ្ឋាភិបាលកម្ពុជា (២០១២)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៣-២០២២។ ក្រសួងអភិវឌ្ឍន៍ជនបទ។ រាជធានីភ្នំពេញ កម្ពុជា។

ដែរ។ ជាចំណុចកណ្តាល កញ្ចប់ខាងក្រោមហាក់បីដូចជាអាចសម្រេចបាន ប្រសិនបើប្រទេស LDC និង AOSIS គាំទ្រសហភាពអឺរ៉ុបនិងបណ្តាប្រទេសឧស្សាហកម្មលើតម្លាភាព ដូចដែលបានពិភាក្សាកាលពីមុន។

ទីមួយ នៅក្នុងសេចក្តីផ្តើម ឬ នៅក្នុងផ្នែកដែលកំណត់បញ្ហាប្រឈមនិងគោលដៅ កិច្ចព្រមព្រៀងស្ទួលគប្បីទទួលស្គាល់កំណើនហានិភ័យអាកាសធាតុ និង ការបាត់បង់ពាក់ព័ន្ធថាជាបញ្ហាប្រឈមមួយទៀតដ៏សំខាន់ក្នុងការសម្រេចបានគោលដៅចុងក្រោយនៃអនុសញ្ញា។ ប្រការនេះ មិនជំនួសការបាត់បង់និងការខូចខាតនៅក្រោមឬហួសពីការបន្សាំ ជាសំណួររសើបមួយទៀត ប៉ុន្តែ ទទួលស្គាល់ភាពសមស្របរបស់វា ដូចដែលត្រូវបានទាមទារយ៉ាងត្រឹមត្រូវ ដោយប្រទេសកម្ពុជា និង ប្រទេសដទៃទៀត។

ទីពីរ កិច្ចព្រមព្រៀងស្ទួលត្រូវនិយាយយោងដល់ WIM យ៉ាងច្បាស់ ស្តីពីការបាត់បង់និងការខូចខាត[25] ដោយទទួលស្គាល់ថាយន្តការនេះគឺជាឧបករណ៍ដ៏គន្លឹះមួយសម្រាប់ដោះស្រាយការបាត់បង់និងការខូចខាត និង ថាវាគួរទទួលបានការយកចិត្តទុកដាក់និងការគាំទ្រជាប្រចាំនិងរយៈពេលវែង ដែលត្រូវបង្កើនជាបន្តបន្ទាប់ ដើម្បីបំពេញមុខងារដ៏សំខាន់បីរបស់វា។ ដោយធ្វើដូច្នេះ WIM នឹងត្រូវបានគេទទួលស្គាល់ និង ចាក់ឫសយ៉ាងរឹងមាំនៅក្នុងកិច្ចព្រមព្រៀងស្ទួល។

ទីបី និង តាមរយៈសេចក្តីសម្រេច COP ភាគីឯកភាពអភិវឌ្ឍនិងដាក់ឲ្យអនុវត្តនូវកម្មវិធីគាំទ្រមួយតាមសំណើនៃ WIM ដែលពង្រឹងបន្ថែមទៀតនូវសមត្ថភាពស្ថាប័ន ដើម្បីបំពេញមុខងារសំខាន់បីរបស់វា។ ការសម្រេចបែបនេះ នឹងដោះស្រាយចំណុចខ្សោយនៃ WIM

ទីបួន ប្រធាន COP គប្បីត្រូវបានជំរុញឲ្យដាក់បញ្ចូលអភិក្រមនានាសំដៅកាត់បន្ថយហានិភ័យអាកាសធាតុ និង ការបាត់បង់បណ្តាលមកពីអាកាសធាតុ រួមមានការទប់ស្កាត់ហានិភ័យ ការកាត់បន្ថយ ការស្តារនីតិសម្បទា និង សំណង (ជាអាទិ៍ តាមរយៈយន្តការធានារ៉ាប់រង) នៅក្នុងរបៀបវារៈដំណោះស្រាយអាកាសធាតុក្រុងប៉ារីស ដែលប្រហែលជានឹងនាំឲ្យមានគំនិតផ្តួចផ្តើម និង កម្មវិធីផ្សេងៗ ដែលត្រូវបានដាក់ឲ្យអនុវត្តដើម្បីភ្ជិតគម្លាតអាកាសធាតុ និង គាំទ្រការអនុវត្តកិច្ចព្រមព្រៀងស្ទួល និង សេចក្តីសម្រេច COP។

---

[25] យន្តការអន្តរជាតិក្រុងវ៉ាសូវី (WIM) ត្រូវបានបង្កើតនៅ COP ១៩ នៅក្រុងវ៉ាសូវី (ឆ្នាំ ២០១៣) ដោយសេចក្តីសម្រេច COP លេខ 2/CP.19 ដែលកំណត់ឲ្យ WIM "... *បំពេញតួនាទីក្រោមអនុសញ្ញាដើម្បីជំរុញការអនុវត្តអភិក្រមនានាដើម្បីដោះស្រាយការបាត់បង់និងការខូចខាតទាក់ទីននឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ, (...) ក្នុងលក្ខណៈពេញលេញ ចម្រុះ និង ប្រកបដោយសង្គតិភាព។*

ប្រទេសកម្ពុជា មានចំណាប់អារម្មណ៍ខ្លាំងក្នុងការទទួលបានការគាំទ្រអន្តរជាតិថែមទៀតដើម្បីពង្រឹងយុទ្ធសាស្ត្ររបស់ខ្លួន។ អាស្រ័យហេតុនេះ កម្ពុជានឹងទទួលផលប្រយោជន៍ពីអភិក្រមកាន់តែទូលាយមួយចំពោះហិរញ្ញប្បទានអាកាសធាតុ ការកសាងសមត្ថភាព និង ការផ្ទេរបច្ចេកវិទ្យា ដោយប្រើឧបករណ៍ផ្សេងៗ។

ការធានាឲ្យបាននូវហិរញ្ញប្បទានអាកាសធាតុគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាពរយៈពេលវែងក្នុងទឹកប្រាក់យ៉ាងហោចណាស់ចំនួន ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំយ៉ាងយូរបំផុតមុនឆ្នាំ ២០២០ ដែលត្រូវបានផ្តល់ដោយប្រទេសអភិវឌ្ឍ និងប្រទេសដទៃទៀតដែលមានលទ្ធភាពធ្វើដូច្នេះបាន គឺជាអាទិភាពមួយនៃប្រទេស LDC និង ប្រទេសកំពុងអភិវឌ្ឍ ៧៧ (G77) និង ប្រទេសចិន។[26] ប្រទេសអភិវឌ្ឍ និងជាពិសេស ប្រធាន COP យល់ពីភាពសមស្របខ្ពស់នៃបញ្ហាហិរញ្ញវត្ថុដើម្បីសម្រេចលទ្ធផលក្រុងប៉ារីសប្រកបដោយអត្ថន័យ។ ប្រទេសកម្ពុជា គប្បីជំរុញឲ្យប្រទេសអភិវឌ្ឍបង្ហាញភាពជាអ្នកដឹកនាំនិងភស្តុតាងអំពីរបៀបដែលពួកគេនឹងបង្កើនការគាំទ្ររបស់ពួកគេ រួមទាំងការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា។ វាអាចគឺជាគំនិតល្អ ដែលត្រូវអនុវត្តយុទ្ធសាស្ត្រពីរផ្លូវ: ទីមួយ រួមជាមួយក្រុមប្រទេសកំពុងអភិវឌ្ឍ ៧៧ (G77) និង ចិន ដាក់សម្ពាធលើប្រទេសអភិវឌ្ឍ គប្បីត្រូវបន្តដើម្បីប្តេជ្ញាចំពោះផែនទីបង្ហាញផ្លូវមួយអំពីរបៀបកៀងគរថវិកា ១០០ពាន់លានដុល្លារមុនឆ្នាំ ២០២០។ ទីពីរ ដោយសហការជាមួយប្រទេស LDC និង SIDS ការគាំទ្រដោយឡែករបស់ប្រទេសអភិវឌ្ឍចំពោះបណ្តាប្រទេសងាយរងគ្រោះទាំងឡាយ អាចត្រូវបានស្នើសុំ។

ចំពោះការទាមទារដ៏ខ្លាំងក្លាដោយប្រទេស LDC នូវការផ្តល់មូលនិធិ "ថ្មីនិងបន្ថែម" ពោលគឺ បន្ថែមលើជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) វាមិនទំនងជាទទួលជោគជ័យច្រើនទេនៅប៉ារីស: ប្រទេសអភិវឌ្ឍទាំងអស់ រ៉ាប់រងផ្តល់ហិរញ្ញប្បទានអាកាសធាតុស្ទើតែទាំងអស់ដែលត្រូវបានផ្តល់ជា ODA ហើយពួកគេមិនទំនងជានឹងផ្លាស់ប្តូរអភិក្រមនេះទេនៅប៉ារីស។ ប៉ុន្តែ ជាជំហានសំខាន់ទីមួយ តម្លាភាពនៃហិរញ្ញប្បទានអាកាសធាតុអន្តរជាតិអាចត្រូវបានកែលម្អ រួមទាំងនិយមន័យឯកភាពគ្នានៃហិរញ្ញប្បទានអាកាសធាតុ ការបែងចែករវាងហិរញ្ញប្បទានអាកាសធាតុដោយស្ថាប័នសាធារណៈ និងឯកជន ឲ្យតែវាស្ថិតនៅក្នុងការសន្យា ១០០ ពាន់លានដុល្លារនោះ និង អាចរហូតដល់ទៅគោលការណ៍ដែលបានឯកភាពគ្នា។ ក្រៅពីធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អន្តរជាតិដទៃទៀតដែលបានបង្ហាញចំណាប់អារម្មលើការបំភ្លឺស្តីពីហិរញ្ញប្បទានអាកាសធាតុ ប្រទេសអាល្លឺម៉ង់ គឺជា

[26] https://ldcclimate.files.wordpress.com/2013/12/ldcp13_adp.pdf ទំព័រ ៧

សក្តានុពលសម្ព័ន្ធមិត្តមួយ ដែលមានចំណាប់អារម្មណ៍ខ្លាំងលើការកែលម្អតម្លាភាព នៃហិរញ្ញប្បទានអាកាសធាតុ។

ជាក់ស្តែង ភាពចាំបាច់នៃការកែលម្អការកសាងសមត្ថភាព ជាប់ចំណាត់ថ្នាក់ខ្ពស់នៅក្នុងបញ្ជីអាទិភាពកម្ពុជា ប៉ុន្តែ គួរឲ្យស្តាយ មិនត្រូវបានចាត់ថ្នាក់ខ្ពស់ដូចគ្នានៅក្នុងរបៀបវារៈក្រុងប៉ារីស។ ដើម្បីដោះស្រាយគម្លាតនេះ សូមផ្តល់អនុសាសន៍សូមឲ្យកម្ពុជាដាក់បញ្ចូលភាពចាំបាច់នៃការកសាងសមត្ថភាពជាក់លាក់របស់ខ្លួននៅក្នុង INDC របស់ប្រទេស។ ក្នុងន័យដូចគ្នានេះដែរ ប្រទេសជិតខាង និង ប្រទេស LDC ដទៃទៀតអាចត្រូវបានលើកទឹកចិត្តដោយប្រទេសកម្ពុជាឲ្យធ្វើដូចគ្នា។ ប្រការនេះនឹងជួយបង្កើនភាពសមស្របផ្នែកនយោបាយនៃបញ្ហានេះ និង អាចជួយប្រទេសកម្ពុជាក្នុងការរកបានការគាំទ្រដើម្បីដោះស្រាយគម្លាតរបស់ខ្លួន។

## ការត្និតគម្លាតមហិច្ឆតាមុនឆ្នាំ ២០២០

យោងតាមទស្សនៈរបស់ក្រុមប្រទេស LDC និង ដែលត្រូវបានគាំទ្រដោយវិទ្យាសាស្ត្រ ឆ្នាំបញ្ចេញឧស្ម័នកំពូលមុនឆ្នាំ ២០២០ គឺសំខាន់ក្រៃលែងសម្រាប់រក្សាលទ្ធភាពប្រាកដនិយមឲ្យនៅក្រោមកម្រិតសីតុណ្ហភាព ១.៥/២°C។

បណ្តាប្រទេសបញ្ចេញឧស្ម័នធំៗ មិនទំនងជានឹងបង្កើនការការសន្យារបស់ពួកគេនៅមុនពេល ក្នុងអំឡុងពេល ឬ ភ្លាមៗក្រោយ COP ២១ តាមសំណើរបស់ប្រទេស LDC ដើម្បីភ្ជិតគម្លាតដ៏ធំមុនឆ្នាំ ២០២០[27] – ហើយហានិភ័យមានកម្រិតខ្ពស់ដែលការប្រែប្រួលអាកាសធាតុរលាយបាត់ចេញពីបញ្ជីអាទិភាពនយោបាយក្នុងបណ្តាឆ្នាំខាងមុខ ក្រោយពេលដែលកិច្ចព្រមព្រៀងក្រុងប៉ារីសត្រូវបានសម្រេច។ ដើម្បីជៀសវាងហានិភ័យនេះ និង ដើម្បីរក្សាសម្ពាធចាំបាច់ កម្ពុជា និង ក្រុមប្រទេស LDC ត្រូវបានផ្តល់អនុសាសន៍ឲ្យបន្តជំរុញបណ្តាភាគី ជាពិសេសស បណ្តាប្រទេសអភិវឌ្ឍ និង ប្រទេសបញ្ចេញឧស្ម័នធំៗដទៃទៀត ឲ្យបង្កើនការសន្យាមុនឆ្នាំ ២០២០ របស់ពួកគេ ឲ្យចាត់វិធានការបន្ថែម និង ឲ្យផ្តល់មធ្យោបាយអនុវត្តកែលម្អ ដល់សកម្មភាពកាត់បន្ថយ របស់ប្រទេសកំពុងអភិវឌ្ឍ។ ប្រការនេះ អាចនាំទៅដល់ការចាប់ផ្តើមគំនិតផ្តួចផ្តើមបន្ថែម និង សេចក្តីប្រកាសនយោបាយ។ លើសពីនេះ កម្ពុជា និង ក្រុមប្រទេស LDC ត្រូវបានជំរុញឲ្យអំពាវនាវឲ្យមានសេចក្តីសម្រេច COP ដ៏រឹងមាំមួយ ដោយស្នើឲ្យភាគីទាំងអស់ធ្វើសកម្មភាពបន្ថែមទៀតដើម្បីភ្ជិតគម្លាតមុនឆ្នាំ ២០២០។ ដើម្បីវាយតម្លៃ និង តាមដានវឌ្ឍនភាពពាក់ព័ន្ធ និង ដើម្បីធានាឲ្យបាននូវការយកចិត្តទុកដាក់ផ្នែកនយោបាយចាំបាច់ សេចក្តីសម្រេច COP ដែលបានស្នើឡើងគប្បីរួមមានការបន្តកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីប្រចាំឆ្នាំ ក្រោមលំហូរការងារទី ២ នៃ ADP។

---

[27] https://ldcclimate.files.wordpress.com/2013/12/ldcp13_adp.pdf, ទំព័រ ២

## ឧបសម្ព័ន្ធ

## អំពីអ្នកនិពន្ធ

*លោក តូម៉ាស ហឺស្ស (Thomas Hirsch)* អ្នកថតរូប និង អ្នកវិទ្យាសាស្ត្រផ្នែកនយោបាយអាល្លឺម៉ង់ ស្ថាបនិកនៃអង្គការផ្តល់ឱវាទផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice) ដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ លើគោលនយោបាយអាកាសធាតុ បរិស្ថាន និង អភិវឌ្ឍន៍ បានចាប់ផ្តើការងារជាសាស្ត្រាចារ្យសកលវិទ្យាល័យ និង ជាទីប្រឹក្សាផ្នែកគោលនយោបាយ និង បានកាន់មុនតំណែងដឹកនាំនៅក្នុងអង្គការអន្តរជាតិផ្នែបរិស្ថាននិងសិទ្ធិមនុស្ស និង ជាទីប្រឹក្សានៃអង្គការសម្ព័ន្ធភាព ACT (ACT Alliance)។

*លោក ធីថានការ ម៉ែដាល (Tirthankar Mandal)* អ្នកសេដ្ឋកិច្ចឥណ្ឌា អ្នកសរសេរកាសែត អ្នកពិគ្រោះការ និង ជាអ្នកស្រាវជ្រាវនៃអង្គការផ្តល់ឱវាទផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice) ដែលមានបទពិសោធន៍ ១០ ឆ្នាំលើគោលនយោបាយអាកាសធាតុ និង ថាមពល បានចាប់ផ្តើមការងារជាអ្នកស្រាវជ្រាវ និង អ្នកវិភាគ បានបំពេញការងារនៅអង្គការ WWF, CANSA និង មូលនិធិ Vasudha Foundation។

## ដៃគូសម្ភាសន៍

| | |
|---|---|
| លោក ទេព ប៊ុននី | ប្រធានក្រុមប្រឹក្សាភិបាលនៃបណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCN) |
| លោកស្រី ហ៊ីង ភាព៉ានិច | អ្នកវិភាគការប្រែប្រួលអាកាសធាតុនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) |
| លោក អ៊ុក ណាវ៉ាន់ | អគ្គនាយករងនៃក្រសួងបរិស្ថាន កម្ពុជា |
| លោក ស៊ូ សុជាតិ | នាយកប្រតិបត្តិនៃអង្គការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន កម្ពុជា (Live and Learn Environmental Education) |

## ឯកសារសិក្សា

ACT Alliance (2015): Paris Expectation Paper

CAN (2015): Legal issues for the 2015 agreement

CBS (2015): Credible Package for Paris

Ad hoc Working Group of the Durban Platform for Enhanced Action (2015): Negotiating Text

Ad hoc Working Group of the Durban Platform for Enhanced Action (2015): Streamlined and consolidated text

Höhne, Niklas et al (2014): Differentiated mitigation commitments in a new climate agreement. LDC paper Series

Ousman Jarju, Pa / Gore, Tim (2013): Key technical and political issues for the LDCs under the ADP. LDC Paper Series

Roberts, Erin et al (2014): Developing an institutional framework to address loss and damage. LDC paper Series

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០១៣): ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៤-២០២៣

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០១២): ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៣-២០២២

UNFCCC Secreatriat (2014): Lima Call for Action

UNFCCC Secretariat (2015): Updated information on ADP facilitators and co-facilitators

UNFCCC Secretariat (2015): Co-chairs’ suggestions on the way forward for ADP preparation

Unknown (2015): CSOs Perspective on Cambodian INDC

## តារាងម៉ាទ្រីសនៃប្រទេសសំខាន់ៗ
## ការចង់បាន និង អាទិភាពរបស់ពួកគេ

| ក្រុមប្រទេស | ប្រព័ន្ធផ្អែកលើវិធាន | មហិច្ឆតាកាត់បន្ថយ | មហិច្ឆតាផ្នែកហិរញ្ញវត្ថុ | មហិច្ឆតាភាពធន់ |
|---|---|---|---|---|
| ចិន | សន្យាមិនពិនិត្យឡើងវិញ | មហិច្ឆតាទាប | ជំរុញការផ្តល់មូលនិធិត្បូង-ត្បូង | មហិច្ឆតាទាប |
| សហរដ្ឋអាមេរិក | សន្យាមិនពិនិត្យឡើងវិញ | មហិច្ឆតាទាប | ជំរុញការវិនិយោគឯកជន | មហិច្ឆតាទាប |
| សហភាពអឺរ៉ុប | ប្រព័ន្ធផ្អែកលើវិធាន | មហិច្ឆតាមធ្យម | មហិច្ឆតាមធ្យម | មហិច្ឆតាទាប |
| LDC | បារម្ភក្រែងមិនអាចទប់ទល់បាន | ការរំពឹងខ្ពស់ | ការរំពឹងខ្ពស់ | អាទិភាព |
| AOSIS | គំនិតខុសគ្នា | មហិច្ឆតាខ្ពស់ | ការរំពឹងខ្ពស់ | ការរំពឹងខ្ពស់ |
| ក្រុមប្រទេសអាហ្វ្រិក | គំនិតខុសគ្នា | គ្មានអាទិភាព | អាទិភាព | ការរំពឹងមធ្យម |
| ILAC | ប្រព័ន្ធផ្អែកលើវិធាន | មហិច្ឆតាមធ្យម | មហិច្ឆតាមធ្យម | មហិច្ឆតា |
| BASIC | គំនិតខុសគ្នា | គំនិតខុសគ្នា | ឧបសម្ព័ន្ធ ១ ត្រូវសម្រេច | គ្មានអាទិភាព |
| ក្រុមប្រទេសមានគំនិតដូចគ្នា | រក្សាជញ្ជាំងការពារ | ឧបសម្ព័ន្ធ ១ ធ្វើសកម្មភាព | ឧបសម្ព័ន្ធ ១ ត្រូវសម្រេច | ឧបសម្ព័ន្ធ ១ ត្រូវសម្រេច |

ប្រភព: តូម៉ាស ហឺស្ស (Thomas Hirsch) អង្គការផ្តល់ឱវាទផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice)

## ការរំពឹងរបស់កម្ពុជាធៀបនឹងក្រុមសំខាន់ៗ

ប្រទេសអភិវឌ្ឍន៍តិចតួច (ប្រទេស LDC) – ក្រុមប្រទេស LDC

ប្រទេសអភិវឌ្ឍទាបបំផុត (ប្រទេស LDC) គឺជាក្រុមមួយនៃបណ្តាក្រុមប្រទេសគាំទ្រដ៏ខ្លាំងបំផុតនៃការមានការព្រមព្រៀងគ្នាប្រកបដោយមហិច្ឆតាមួយនៅ COP២១។ បណ្តាប្រទេសទាំងនេះ ក៏គឺជាប្រទេសដែលគាំទ្រផងដែរ នូវមាតិកាពីលើចុះក្រោមផ្អែកលើវិទ្យាសាស្ត្រ ដែលត្រូវឯកភាពគ្នានៅ COP ២១។

បណ្តាប្រទេសមានសេដ្ឋកិច្ចងើបឡើងថ្មី – ក្រុមប្រទេស BASIC ប្រទេសឥណ្ឌូណេស៊ី ម៉ិកស៊ិក្ង និងប្រទេសដទៃទៀត

កម្ពុជា ជឿថាបណ្តាប្រទេសមានសេដ្ឋកិច្ចងើបឡើងថ្មីគប្បីដោះស្រាយបញ្ហាប្រឈមនៃការលើកកម្ពស់ចំណុចដៅកាត់បន្ថយរបស់ខ្លួនពីកម្រិតបច្ចុប្បន្ន។ គេជឿថាបណ្តាប្រទេសនានា ដូចជា សឹង្ហបុរី កាតា កូរ៉េខាងត្បូង អាចបង្កើនការសន្យារបស់ខ្លួនក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ហើយពួកគេគប្បីសន្យាធ្វើដូច្នេះនៅ COP២១ ដើម្បីធ្វើឲ្យសន្និសីទនេះទទួលបានជោគជ័យ។ ប្រទេសនានា ដូចជាប្រទេសឥណ្ឌា ជាដើម ដែលមានសមត្ថភាព និង មានបញ្ហាប្រឈមផ្នែកអភិវឌ្ឍន៍ ក៏គប្បីបង្កើនមហិច្ឆតារបស់ខ្លួនផងដែរពីកម្រិតបច្ចុប្បន្ន។ ប្រការនេះ នឹងជួយក្រុមប្រទេសកំពុងអភិវឌ្ឍ ៧៧ (G77) និង ប្រទេសចិនក្នុងការបង្កើនសម្ពាធលើប្រទេសអភិវឌ្ឍ។

បណ្តាប្រទេសជាតិអាស៊ីអគ្នេយ៍

ក្រុមប្រទេសអាស៊ាន (ASEAN) ដែលរួមមានប្រទេសជាតិអាស៊ីអគ្នេយ៍ គឺជាក្រុមប្រទេសសង្កេតការណ៍មួយនៃ UNFCCC។ ប្រទេសកម្ពុជា យល់ថាអាស៊ានគប្បីសហការ និង ធ្វើការឆ្ពោះទៅកាន់កិច្ចព្រមព្រៀងប្រកបដោយមហិច្ឆតាមួយនៅប៉ារីស។ ចំណុចនេះ ក៏នឹងជួយសម្រួលផងដែរ ដល់កិច្ចសហការក្នុងតំបន់កាន់តែច្រើនឡើង។ ដោយសារមានផលប្រយោជន៍រួមនៅក្នុងបញ្ហានានាដូចជាការបន្សាំ ការបាត់បង់និងការខូចខាត និង ការអភិវឌ្ឍដែលបញ្ចេញកាបូនទាប បណ្តាប្រទេសទាំងនេះអាចអភិវឌ្ឍយុទ្ធសាស្ត្ររួម។

សហភាពអឺរ៉ុប

កម្ពុជាចាត់ទុក INDC នៃសហភាពអឺរ៉ុបថាមិនមានមហិច្ឆតាគ្រប់គ្រាន់។ កម្ពុជារំពឹងថាសហភាពអឺរ៉ុបនឹងបង្កើនជាឯកតោភាគីនូវចំណុចដៅរបស់ខ្លួន ដើម្បីផ្តួចផ្តើមមហិច្ឆតាឆ្ពោះឡើងទៅលើ។

<u>សហរដ្ឋអាមេរិក</u>

កម្ពុជា រំពឹងថាសហរដ្ឋអាមេរិកនឹងធ្វើកាន់តែច្រើន។ ភាគទានគ្រោងដែលបានសម្រេចនៅថ្នាក់ជាតិ (INDC) ត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់ ចំពោះមុខអ្វីដែលចាំបាច់ដើម្បីស្ថិតនៅកម្រិតសីតណ្ហភាពក្រោម ១.៥°C។ ចំណុចនេះ ក៏មានលក្ខណៈដូចគ្នាដែរចំពោះហិរញ្ញប្បទានអាកាសធាតុ។ កម្ពុជា ជឿថាចលនាមួយរបស់សហរដ្ឋអាមេរិកអាចជំរុញឲ្យមានការព្រៀមព្រៀងមួយកាន់តែមានមហិច្ឆតាខ្ពស់។




ប្រភព: តូម៉ាស ហឺស្ស (Thomas Hirsch) អង្គការផ្តល់ឱវាទផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice)




ប្រភព: ប្រភព: តូម៉ាស ហឺស្ស (Thomas Hirsch) អង្គការផ្តល់ឱវាទផ្នែកអាកាសធាតុ និង អភិវឌ្ឍន៍ (Climate & Development Advice)

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

DAN CHURCH AID
AYUDA DE DCA
actalliance
DENMARK

christian aid

JOINT PROGRAMME | MEMBERS OF actalliance

EUROPEAN COMMISSION

Humanitarian Aid and Civil Protection